គាំទ្រស្ត្រី

ប្រយុទ្ធនឹងភាពក្រីក្រ

# គោលនយោបាយស្តីពីកិច្ចការពារកុមារ
# នៃអង្គការឃែរអូស្ត្រាលី

ខែកក្កដា ឆ្នាំ2022

# មាតិកា


**សេចក្តីផ្តើម** **3**

គោលការណ៍ 3

គោលបំណងនៃគោលនយោបាយ **3**

ដែនអនុវត្តន៍ **4**

3.1 ភាពជាដៃគូជាមួយនឹងអង្គការផ្សេងៗ 4

សេចក្តីលម្អិតគោលនយោបាយ **5**

4.1 ការយល់ដឹង 5

4.2 ការបណ្តុះបណ្តាល និងការអភិវឌ្ឍ 5

4.3 ការវាយតម្លៃហានិភ័យ 5

4.4 វិធីសាស្រ្តផ្តោតលើអ្នកជនរងគ្រោះ 6

4.5 ការជ្រើសរើស និងការសម្រិតសម្រាំងបុគ្គលិក 6

4.6 ក្រមសីលធម៌ 8

4.7 ការប្រើប្រាស់ រូបថត រូបភាព វីដេអូ និងព័ត៌មានអំពីកុមារ 8

4.8 ការរាយការណ៍ 9

4.9 ការឆ្លើយតបចំពោះការរាយការណ៍ 10

គោលនយោបាយពាក់ព័ន្ធ និងនីតិវិធីនានា **12**

ឯកសារគាំទ្រ និងឯកសារយោង **12**

6.1 លិខិតបទដ្ឋានគតិយុត្តិ 12

6.2 ឯកសាររបស់អង្គការឃែរអូស្រ្តាលី និងអង្គការឃែរអន្តរជាតិ 13

6.3 ឧបសម្ព័ន្ធ 13

ច្បាប់ **13**

ការអនុវត្ត និង ការទំនាក់ទំនង **13**

សេចក្តីលម្អិតគោលនយោបាយ **13**

និយមន័យ **14**

ឧបសម្ព័ន្ធ 1 **16**

លក្ខខណ្ឌតម្រូវនៃកិច្ចការពារកុមារ 16

ឧបសម្ព័ន្ធ 2 **17**

ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ 17

ឧបសម្ព័ន្ធ 3 **21**

ការទទួលស្គាល់ថាបានទទួលក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ 21

# 1. សេចក្តីផ្តើម

## គោលការណ៍

អង្គការយៃរអូស្ត្រាលី (CA) ប្តេជ្ញាចិត្តលើកកម្ពស់ និងការពារផលប្រយោជន៍ និងសុវត្ថិភាពកុមារ។ យើងខ្ញុំមិនអត់ឱនជាដាច់ខាត ចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ ។

បុគ្គលគ្រប់រូបដែលធ្វើការឱ្យ ឬធ្វើការជាមួយអង្គការយៃរអូស្ត្រាលី ទទួលខុសត្រូវថែរក្សា និងការពារកុមារ ហើយត្រូវរាយការណ៍ព័ត៌មានអំពីការរំលោភបំពានកុមារ ឬការកេងប្រវ័ញ្ចកុមារនោះ។ ហើយនៅក្នុងករណីដែលមានការរាយការណ៍ នោះយើងខ្ញុំត្រូវប្រើប្រាស់វិធីសាស្ត្រផ្តោតលើជនរងគ្រោះ ហើយធានាថាដំណើរការទាំងអស់ពិតជាគាំទ្រការចូលរួមរបស់កុមារ។

នៅគ្រប់សកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ នោះត្រូវពិចារណាលើឧត្តមប្រយោជន៍របស់កុមារជាចម្បង។

អង្គការយៃរអូស្ត្រាលីទទួលស្គាល់ថាកុមារនៅក្នុងសហគមន៍ ដែលអង្គការប្រតិបត្តិការងាររបស់ខ្លួន គឺជាក្រុមកុមារដែលងាយរងគ្រោះ ហើយក៏ទទួលស្គាល់ផងដែរថាសហគមន៍ទាំងនោះត្រូវតែពឹងផ្អែកលើការប្តេជ្ញាចិត្តរបស់អង្គការយៃរអូស្ត្រាលីដើម្បីបង្កើតអង្គការមួយដែលមានសុវត្ថិភាពសម្រាប់កុមារ។

អង្គការយៃរអូស្ត្រាលីតម្រូវឱ្យមានការគាំទ្រ និងកិច្ចសហប្រតិបត្តិការដោយបុគ្គលគ្រប់រូប ដែលយើងធ្វើការជាមួយដើម្បីធានាថាយើងគ្រប់គ្រងហានិភ័យទាំងនោះចំពោះកុមារប្រកបដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាលនៃអង្គការយៃរអូស្ត្រាលីទទួលខុសត្រូវចំពោះគោលនយោបាយស្តីពីកិច្ចការពារកុមារនេះនិងតម្រូវឱ្យមានការរាយការណ៍ជាទៀងទាត់ពីថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រង អំពីការអនុវត្តគោលនយោបាយ និងអំពីហានិភ័យ ដើម្បីតម្រង់ផ្លូវសម្រាប់អង្គការ។

# 2. គោលបំណងនៃគោលនយោបាយ

គោលបំណងនៃគោលនយោបាយនេះ គឺ ៖

- បញ្ជាក់នូវការប្តេជ្ញាចិត្តរបស់អង្គការយៃរអូស្ត្រាលីចំពោះការផ្តល់សុខុមាលភាព និងការការពារដល់កុមារមិនឱ្យទទួលរងនូវការរំលោភបំពាន និងការកេងប្រវ័ញ្ច។
- សម្របសម្រួលការទប់ស្កាត់ និងកាត់បន្ថយហានិភ័យនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារ ដែលកើតឡើងនៅក្នុងសហគមន៍ ដែលអង្គការយៃរអូស្ត្រាលីមានវត្តមាន។
- អនុវត្តវប្បធម៌អង្គការដែលលើកកម្ពស់ការរក្សាសុវត្ថិភាពកុមារ។
- ដោះស្រាយចំពោះហានិភ័យដែលជនល្មើសផ្លូវភេទ កំណត់ជាគោលដៅ និងព្យាយាមជ្រៀតចូលទៅក្នុងអង្គការ ដូចជាអង្គការយៃរអូស្ត្រាលី និងអង្គការដៃគូរបស់យើងខ្ញុំ ដើម្បីចូលពាក់ព័ន្ធជាមួយនឹងកុមារបាន។
- ធានាថាគ្រប់ភាគីទាំងអស់ ពិតជាបានដឹងអំពីការទទួលខុសត្រូវរបស់ពួកគេ នៅក្នុងការកំណត់នូវឱកាសជាយថាហេតុ ដែលអាចនឹងប្រព្រឹត្តិការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារបាន និងនៅក្នុងការបង្កើតការគ្រប់គ្រង និងបង្កើតនីតិវិធីនានា សម្រាប់ទប់ស្កាត់ការរំលោភបំពានទាំងនោះ និង/ឬស្រាវជ្រាវស៊ើបអង្កេតរកការរំលោភបំពាននោះ នៅពេលមានករណីកើតឡើង។
- ផ្តល់ការណែនាំដល់បុគ្គលិក/អ្នកស្ម័គ្រចិត្ត/អ្នកផ្តល់សេវាពីខាងក្រៅ/ភ្ញៀវ[1]អំពីវិធានការដែលត្រូវអនុវត្តនៅក្នុងករណីដែលពួកគេសង្ស័យថាមានការរំលោភបំពានកុមារ ឬការកេងប្រវ័ញ្ចកុមារ។
- ធ្វើការបញ្ជាក់ច្បាស់លាស់ដល់បុគ្គលិក/អ្នកស្ម័គ្រចិត្ត/អ្នកផ្តល់សេវាពីខាងក្រៅ/ភ្ញៀវ ដែលត្រូវទប់ស្កាត់ការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារនោះមិនឱ្យកើតឡើង។
- ធានាថានៅគ្រប់ករណីសង្ស័យទាំងអស់ដែលមានការរំលោភបំពាន ត្រូវធ្វើការរាយការណ៍ និងធ្វើការស៊ើបអង្កេតពេញលេញ។
- ធានាថាបុគ្គលិកទាំងអស់ ដែលអ្នកពាក់ព័ន្ធនៅក្នុងគម្រោងដែលគ្រប់គ្រង ឬផ្តល់ថវិកាដោយអង្គការយៃរអូស្ត្រាលី នឹងត្រូវបានបណ្តុះបណ្តាលអំពីកិច្ចការពារកុមារ និងពួកគេពិតជាយល់ដឹងអំពីកាតព្វកិច្ចរបស់ពួកគេនៅក្នុងការការពារកុមារ នៅពេលបំពេញការងារ រួមទាំងការអនុវត្តគោលនយោបាយនេះផងដែរ។

# 3. ដែនអនុវត្តន៍

គោលនយោបាយអនុវត្តចំពោះករណីខាងក្រោម ៖

- បុគ្គលិកទាំងអស់របស់អង្គការយៃរអូស្ត្រាលី អ្នកស្ម័គ្រចិត្ត និងអ្នកហាត់ការ រួមទាំងសមាជិកក្រុមប្រឹក្សា ភិបាលទីប្រឹក្សារបស់ក្រុមប្រឹក្សាភិបាល និងអ្នកសង្កេតការណ៍របស់ក្រុមប្រឹក្សាភិបាល (បុគ្គលិករបស់អង្គការយៃរអូស្ត្រាលី)។
- បុគ្គលិកទាំងអស់ អ្នកស្ម័គ្រចិត្ត និងអ្នកហាត់ការ នៅអង្គការយៃរអន្តរជាតិប្រចាំប្រទេស ដែលអង្គការយៃរអូស្ត្រាលីគឺជាអ្នកដឹកនាំសកម្មភាពការងារ នោះបុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកហាត់ការនៃអង្គការយៃរអន្តរជាតិប្រចាំប្រទេស ដែលពាក់ព័ន្ធដោយផ្ទាល់ នៅក្នុងការអនុវត្តកម្មវិធី ឬគម្រោង ដែលគ្រប់គ្រង ឬផ្តល់ថវិកាទាំងមូល ឬមួយចំណែកដោយ អង្គការយៃរអូស្ត្រាលី (តទៅនេះហៅថាដៃគូអង្គការយៃរ)។

ពាក្យ "សហការីអង្គការយៃរ" ឬ "សហសេវិកអង្គការយៃរ" ត្រូវបានប្រើប្រាស់ពេញមួយគោលនយោបាយនេះដើម្បី

[1] សូមមើលសេចក្តីលម្អិតថាតើបុគ្គលណាខ្លះដែលក្រមសិលធម៌នេះរាប់បញ្ចូលនៅក្នុងចំណុចទី 3--ដែនអនុវត្តន៍

សំដៅដល់បុគ្គលិករបស់អង្គការយែរអូស្ត្រាលី និងដៃគូនៃអង្គការយែរអូស្ត្រាលី ។

- អ្នកផ្តល់សេវាពីខាងក្រៅដែលជួលដោយអង្គការយែរអូស្ត្រាលី ឬដោយដៃគូនៃអង្គការយែរអូស្ត្រាលី ជួសមុខឱ្យអង្គការយែរអូស្ត្រាលី ដែលមានការប្រាស្រ័យទាក់ទងជាមួយនឹងកុមារ។ ចំណុចនេះរាប់បញ្ចូលអ្នកចុះកិច្ចសន្យា ទីប្រឹក្សា អាជីវករ និងកុងស៊ុលតង់ ហើយនិងដៃគូផ្សេងៗ (រួមមានដៃគូបន្ត) ឬអង្គការផ្សេងៗ ដែលទទួលបានការឧបត្ថម្ភថវិកា ឬបានចុះកិច្ចសន្យាបន្តជាមួយនឹងអង្គការយែរអូស្ត្រាលី ឬដៃគូនៃអង្គការយែរអូស្ត្រាលី រួមទាំងបុគ្គលិកម្នាក់ៗរបស់ដៃគូទាំងនោះផងដែរ ដែលមានការប្រាស្រ័យទាក់ទងជាមួយនឹងកុមារ (ដៃគូ)។

ការប្តេជ្ញាចិត្តរបស់អង្គការយែរអូស្ត្រាលីដើម្បីការពារសុវត្ថិភាព និងឧត្តមប្រយោជន៍របស់កុមារត្រូវតែដាក់បញ្ចូលនៅក្នុងអំឡុងពេលនៃការចុះពិនិត្យមើលគម្រោងដែលគ្រប់គ្រង ឬផ្តល់ថវិកាដោយអង្គការយែរអូស្ត្រាលី ដែលធ្វើឡើងដោយបុគ្គលគ្រប់រូប រួមទាំងម្ចាស់ជំនួយ មន្ត្រីរដ្ឋាភិបាល ឬសមាជិកគ្រួសាររបស់បុគ្គលិករបស់អង្គការយែរ អូស្ត្រាលី (ភ្ញៀវ)ផងដែរ។ យ៉ាងនេះក្តី អង្គការយែរអូស្ត្រាលីទទួលស្គាល់ថាដំណើរការមួយចំនួនដែលមានចែងនៅក្នុងគោលនយោបាយនេះ អាចនឹងមិនអនុវត្តទេ ឬមិនសមស្របចំពោះភ្ញៀវទាំងនោះឡើយ។ ជាជំនួសមកវិញការត្រួតពិនិត្យលើការអនុវត្ត នៅអំឡុងពេលចុះពិនិត្យមើល និងការធានាសុវត្ថិភាពកុមារ គឺជាការទទួលខុសត្រូវរបស់អង្គការយែរអូស្ត្រាលី ឬថ្នាក់គ្រប់គ្រងរបស់ដៃគូនៃអង្គការយែរអូស្ត្រាលី ដែលជាអ្នកសម្របសម្រួលការចុះពិនិត្យមើលទាំងនោះ។

### 3.1 ភាពជាដៃគូជាមួយនឹងអង្គការផ្សេងៗ

អង្គការយែរអូស្ត្រាលីប្តេជ្ញាចិត្តធានាថាបុគ្គលគ្រប់រូបអនុវត្តតាមគោលនយោបាយនេះ។ នេះមានន័យថា សហការីអង្គការយែរ និងដៃគូ ត្រូវ ៖

- ធានាថាបុគ្គលិកខ្លួន យល់ដឹងអំពី កាតព្វកិច្ចរបស់ពួកគេដើម្បីការពារ កុមារ នៅពេលបំពេញការងារ។
- មានយន្តការច្បាស់លាស់សម្រាប់ការផ្តល់យោបល់ពីសហគមន៍ ដែលសមស្របទៅតាមបរិបទតំបន់ពីសំណាក់អ្នកចូលរួមក្នុងកម្មវិធីទាំងអស់អាចផ្តល់ជាយោបល់បាន (ជាពិសេសកុមារ)។
- មានយន្តការរាយការណ៍ ឬនីតិវិធីច្បាស់លាស់សម្រាប់បុគ្គលិកខ្លួនរាយការណ៍អំពីកង្វល់ទៅលើការកេងប្រវ័ញ្ច ឬការរំលោភបំពានកុមារ និង
- រាយការណ៍ភ្លាមៗអំពីករណីសង្ស័យ ឬករណីចោទប្រកាន់ណាមួយទៅលើការកេងប្រវ័ញ្ច ឬការរំលោភបំពានកុមារ។

មានការវាយតម្លៃជាទៀងទាត់មួយត្រូវធ្វើឡើង យ៉ាងតិចណាស់ នៅកម្រិតអប្បបរមារៀងរាល់ ៣ ឆ្នាំ ឬ ញឹកញាប់ជាងនេះ តាមការតម្រូវដោយការវាយតម្លៃហានិភ័យនៃកិច្ចការពារកុមារ និងការអនុវត្តការរក្សាសុវត្ថិភាពកុមារនៃដៃគូដើម្បីធានាថាគោលនយោបាយ និងនីតិវិធីមានសង្គតិភាពត្រូវគ្នា និងអនុវត្តប្រកបដោយអានុភាព។ ការងារនេះនឹងត្រូវធ្វើឡើងដោយ ៖

- ដោយអង្គការយែរអូស្ត្រាលីចំពោះដៃគូរបស់អង្គការ
- ដោយសហការីអង្គការយែរចំពោះដៃគូរបស់ពួកគេ

សហការីអង្គការយែរនឹងគាំទ្រដៃគូនៅក្នុងការពង្រឹងការអនុវត្តការរក្សាសុវត្ថិភាពកុមាររបស់ខ្លួន រួមមានការពិនិត្យមើលគោលនយោបាយ និងការអនុវត្តផ្ទាល់របស់ដៃគូទៅលើកិច្ចការពារកុមារ រួមទាំងការផ្តល់ព័ត៌មាន និង ការបណ្តុះបណ្តាលផងដែរ។

សហការីអង្គការយែរ ក៏នឹងធានាផងដែរថាការចូលរួមពាក់ព័ន្ធរបស់ដៃគូ ៖

- តាមរយៈអនុម័តគោលនយោបាយនេះ ឬប្រើប្រាស់គោលនយោបាយរបស់ដៃគូនៃអង្គការយែរអូស្ត្រាលី ឬក៏ប្រើប្រាស់គោលនយោបាយស្តីពីកិច្ចការពារកុមារផ្ទាល់របស់ខ្លួនតែម្តងក៏បាន (គោលនយោបាយរបស់ដៃគូ) ប្រសិនបើគោលនយោបាយនោះអនុវត្តស្តង់ដារ និងលក្ខខណ្ឌតម្រូវដូចគ្នា។
- ដាក់បញ្ចូលលក្ខខណ្ឌតម្រូវដែលដៃគូ និងបុគ្គលិកខ្លួនត្រូវគោរពតាមគោលនយោបាយនេះ (ឬ គោលនយោបាយរបស់ដៃគូនៅក្នុងករណីអនុវត្តបាន) រួមទាំងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារនេះផង ដែលនឹងមាន ភាពស្របជាមួយនឹងស្តង់ដារនៅក្នុងគោលនយោបាយនេះ។
- ចែងច្បាស់ថាការខកខានរបស់ដៃគូ និងបុគ្គលិកខ្លួនក្នុងការគោរពតាមគោលនយោបាយនេះ (ឬ គោលនយោបាយរបស់ដៃគូនៅក្នុងករណីអនុវត្តបាន) រួមមានការខកខានក្នុងការរាយការណ៍ភ្លាមៗអំពីករណីសង្ស័យ ឬករណីចោទប្រកាន់ណាមួយពីបទរំលោភបំពានកុមារ ឬការកេងប្រវ័ញ្ចកុមារ ឬពីបទការមិនអនុវត្តគោលនយោបាយ គឺជាសំអាងសម្រាប់អង្គការយែរអូស្ត្រាលីរំលាយកិច្ចព្រមព្រៀងដោយចូលធរមានភ្លាមៗ។

## 4. សេចក្តីលម្អិតនៃគោលនយោបាយ

### 4.1 ការយល់ដឹង

សហការីអង្គការយែរត្រូវធានាថាបុគ្គលគ្រប់រូប ដែលស្ថិតនៅក្នុងដែនអនុវត្តន៍នៃគោលនយោបាយនេះ ពិតជាបានយល់ដឹងអំពីផលវិបាកនៃការកេងប្រវ័ញ្ច និងការបំពានកុមារ និងដឹងពីកត្តានានាដែលអាចបង្កើនភាពងាយរងគ្រោះ និងបង្កហានិភ័យចំពោះកុមារ។ ការដឹង និងការយល់ដឹងនេះ នឹងត្រូវពង្រឹង តាមរយៈការបណ្តុះបណ្តាល

ការទំនាក់ទំនងគ្នាផ្ទៃក្នុង និងការដាក់បញ្ចូលកុមារ សកម្មភាពរក្សាសុវត្ថិភាពកុមារ ទៅក្នុងដំណើរការ និងលំហូរការងារ។

## 4.2 ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍ

សហការីអង្គការយែរ និងដៃគូទាំងអស់ត្រូវទទួលបាននូវព័ត៌មាន ពាក់ព័ន្ធនឹងគោលនយោបាយស្ដីពីកិច្ចការពារកុមារ និងក្រមសីលធម៌ស្ដីពីកិច្ចការពារកុមាររបស់អង្គការយែរអូស្ដ្រាលី (ដូចមានចែងនៅក្នុងផ្នែក 4.7 ខាងក្រោម) នៅក្នុងករណីដែលគោលនយោបាយរបស់ដៃគូ និងក្រមសីលធម៌ស្ដីពីកិច្ចការពារកុមារមិនត្រូវបានយកមកប្រើប្រាស់។

ការបណ្ដុះបណ្ដាលស្ដីពីកិច្ចការពារកុមារនិងយន្តការរាយការណ៍ នឹងត្រូវបានគេផ្ដល់ឱ្យសម្រាប់សហការីថ្មីទាំងអស់នៃអង្គការយែរ និងដៃគូនៅពេលណែនាំតម្រង់ទិសបុគ្គលិក និងនៅពេលណែនាំអំពីកម្មវិធីរបស់អង្គការ ដែលត្រូវធ្វើឡើងជាទៀងទាត់ (រៀងរាល់ ២ ឆ្នាំ)។

## 4.3 ការវាយតម្លៃហានិភ័យ

វិធីសាស្ត្រឆ្លើយតបហានិភ័យរបស់អង្គការយែរអូស្ដ្រាលីបានដាក់បញ្ចូលការវាយតម្លៃជាប្រព័ន្ធ និងការគ្រប់គ្រងហានិភ័យទៅលើការកេងប្រវ័ញ្ច និងការបំពានកុមារ។

ការវាយតម្លៃហានិភ័យបានជួយផ្ដល់ព័ត៌មានសម្រាប់ការរៀបចំ ការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យសកម្មភាពកម្មវិធី ដូច្នេះយើងអាចធានាបានថាពួកគេមានសុវត្ថិភាពចំពោះកុមារ។

និយាយជាក់លាក់ សហការីអង្គការយែរ នឹង ៖

- វាយតម្លៃលក្ខខណ្ឌបរិយាកាស និងភាពងាយរងគ្រោះដែលមានស្រាប់ចំពោះកុមារនៅក្នុងបរិបទគម្រោង។
- កំណត់ប្រភេទ និងវិសាលភាពនៃការទាក់ទងជាមួយនឹងកុមារ ដែលសកម្មភាពគម្រោងត្រូវពាក់ព័ន្ធ។ សូមកត់សម្គាល់ថាការទាក់ទងនេះមានដូចជាការទាក់ទងដោយផ្ទាល់ ឬការទាក់ទងប្រយោល។
- កំណត់ថាតើកិច្ចការពារកុមារ និងការវាយតម្លៃលើការរក្សាសុវត្ថិភាពកុមារ ត្រូវធ្វើឡើងជាចាំបាច់ដែរ ឬទេ ៖
    - ប្រសិនបើមិនមានការទាក់ទងទេ រួមទាំងការទាក់ទងដោយប្រយោលផងដែរនោះ នោះពុំចាំបាច់ធ្វើការវាយតម្លៃហានិភ័យទេ។ សេចក្ដីសម្រេច និងដំណើរការឯកភាពនេះគួរធ្វើឡើងជាឯកសារ។
    - ប្រសិនបើកម្មវិធីមានពាក់ព័ន្ធនឹងការធ្វើការជាមួយ ឬ ការទាក់ទងជាមួយកុមារ (រាប់បញ្ចូលទាំងការទាក់ទងដោយប្រយោលផងដែរ) នោះកិច្ចការពារកុមារ និងការវាយតម្លៃហានិភ័យការរក្សាសុវត្ថិភាពកុមារគួរធ្វើឡើង។ ចំណុចនេះគួរបញ្ចូលការវាយតម្លៃទៅលើដៃគូមានស្រាប់ ឬដៃគូថ្មី និងសមត្ថភាពការពារកុមារ និងរក្សាសុវត្ថិភាពកុមាររបស់ពួកគេ។
- កំណត់ហានិភ័យចំពោះកុមារ រួចហើយកំណត់ថាតើការគ្រប់គ្រងបន្ថែមទៀតអ្វីខ្លះ (ប្រសិនបើមាន) ដែលចាំបាច់ដើម្បីកាត់បន្ថយហានិភ័យ។ សេចក្ដីសម្រេច និងដំណើរការឯកភាពនេះគួររៀបចំទុកជា ឯកសារ។
- កំណត់ពេលវេលា តាមដាន និងរាយការណ៍ថាតើនៅពេលណាដែលត្រូវធ្វើការគ្រប់គ្រង រួចហើយវាយតម្លៃថាតើការគ្រប់គ្រងនោះមានប្រសិទ្ធភាពដែរ ឬទេនៅក្នុងកម្មវិធី ឬរាយការណ៍អំពីប្រសិទ្ធភាពការងារ។
- ពិនិត្យមើល និងធ្វើបច្ចុប្បន្នភាពបញ្ជីហានិភ័យជារៀងរាល់ឆ្នាំ ឬ ញឹកញាប់ជាងនេះនៅក្នុងករណីដែលមានការប្រែប្រួលសំខាន់ៗចំពោះបរិយាកាសធ្វើប្រតិបត្តិការរបស់ខ្លួន។

## 4.4 វិធីសាស្ត្រផ្ដោតលើជនរងគ្រោះ

អង្គការយែរអូស្ដ្រាលីប្ដេជ្ញាចិត្តអនុវត្តវិធីសាស្ត្រផ្ដោតលើជនរងគ្រោះសម្រាប់ការចូលរួមរបស់ខ្លួនជាមួយនឹងជនរងគ្រោះ/អ្នករួចផុតពីគ្រោះ ដែលធ្លាប់បានឆ្លងកាត់ការរំលោភបំពាន ឬការកេងប្រវ័ញ្ច។ នេះមានន័យថានៅក្នុងករណីដែលជនរងគ្រោះគឺជាកុមារ នោះយើង ប្រើប្រាស់វិធីសាស្ត្រផ្ដោតលើកុមារ ស្របពេលគ្នានឹងទទួលស្គាល់ និងគាំទ្របរិបទគ្រួសាររបស់កុមារផងដែរ ទោះជាទង្វើគ្រោះថ្នាក់នោះមានទម្រង់ជាអ្វីក៏ដោយ។ វិធានការទាំងអស់ត្រូវតែសមស្របតាមដំណាក់កាលអភិវឌ្ឍន៍របស់កុមារម្នាក់ៗ និងស្របតាមកាលៈទេសៈ។

កុមារមានសិទ្ធិទទួលបាន ៖

- សិទ្ធិឯកជនភាព និងការរក្សាការសម្ងាត់។
- ទទួលបានប្រព្រឹត្តិកិច្ចប្រកបដោយភាពថ្លៃថ្នូរ និងការគោរព ហើយឥរិយាបទស្ដីបន្ទោសជនរងគ្រោះ នឹងមិនត្រូវបានអត់ឱនឱ្យឡើយ។
- ទទួលបានព័ត៌មានពេញលេញដែលផ្ដល់ឱ្យពួកគេ និងគ្រួសារពួកគេ ជាភាសាសមស្របសម្រាប់អាយុពួកគេ និងធ្វើឡើងតាមរយៈអ្នកបកប្រែ ប្រសិនបើចាំបាច់។
- សិទ្ធិចូលរួមធ្វើសេចក្ដីសម្រេចចិត្តអំពីវិធានការពាក់ព័ន្ធនឹងការរំលោភបំពាន ឬការកេងប្រវ័ញ្ច ដោយសមស្របសម្រាប់អាយុពួកគេ សម្រាប់ដំណាក់កាលអភិវឌ្ឍន៍នៃពួកគេ រួមជាមួយនឹងគ្រួសារ ឬអ្នកគាំទ្រដែលកុមារទុកចិត្ត (ដូចមានចែងនៅក្នុងផ្នែក "ការប្រឹក្សាយោបល់ជាមួយកុមារ")។
- សិទ្ធិមិនទទួលរងការរើសអើង ដោយសារលក្ខណៈសម្បត្តិផ្ទាល់របស់ពួកគេ ឧទាហរណ៍ យេនឌ័រ អាយុ ពូជសាសន៍/ជនជាតិភាគតិច ជំនឿសាសនា ប្រវត្តិគ្រួសារ ឬប្រវត្តិសង្គម មុខតំណែងការងារ សមត្ថភាព ចំណាប់អារម្មណ៍ផ្លូវភេទ ស្ថានភាពផ្ទុកមេរោគអេដស៍ ឬលក្ខណៈសម្បត្តិផ្សេងៗទៀត។

- សិទ្ធិក្នុងការសួរខ្លួនថាតើអ្វីដែលធ្វើឱ្យពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព ឬគ្មានសុវត្ថិភាព និងទទួលបាននូវបរិយាកាសទុកចិត្ត ដែលត្រូវបង្កើតឡើងសម្រាប់ពួកគេ និងជាមួយពួកគេ ដើម្បីលើកទឹកចិត្តពួកគេឱ្យមានអារម្មណ៍ថាមានភាពជឿជាក់គ្រប់គ្រាន់ ក្នុងការបញ្ចេញមតិថាតើពួកគេមានការព្រួយបារម្ភអំពីដំណើរការនោះដែរ ឬទេ ឬមានអារម្មណ៍គ្មានសុវត្ថិភាពដែរ ឬទេ។

សហការីអង្គការយៃរ នឹងបញ្ជូនជនរងគ្រោះអ្នករួចផុតពីគ្រោះថ្នាក់ ទៅអង្គការគាំទ្រ និងអ្នកផ្តល់សេវាថែទាំបន្ទាន់ / ប្រឹក្សាយោបល់ ហើយរ៉ាប់រងចំណាយ/ផ្តល់ជំនួយបឋមឱ្យបានសមរម្យ។

សហការីអង្គការយៃរនឹងធ្វើការជាមួយនឹងអាជ្ញាធររបស់រដ្ឋាភិបាលដែលបានបង្កើតឡើង ដើម្បីគាំទ្រការឆ្លើយតបចំពោះកុមារនៅក្នុងករណីសុវត្ថិភាពដែលអាចធ្វើបាន។

## 4.5 ការជ្រើសរើស និងការសម្រិតសម្រាំងបុគ្គលិក

សហការីអង្គការយៃរនឹងមិនជួល ឬប្រគល់ការងារដោយចេតនាទៅឱ្យបុគ្គលណាម្នាក់ដែលបង្កហានិភ័យចំពោះកុមារឡើយ។ អង្គការយៃរអូស្ត្រាលីប្តេជ្ញាចិត្តទប់ស្កាត់មិនឱ្យមានជនណាដែលធ្វើការជាមួយកុមារបានទេ បើជននោះបង្កហានិភ័យ/គ្រោះថ្នាក់ចំពោះកុមារ។

សហការីអង្គការយៃរត្រូវប្រកាន់ខ្ជាប់តាមការណែនាំ នៅក្នុងដំណើរការជ្រើសរើសបុគ្គលិក។ គោលការណ៍ណែនាំជ្រើសរើសបុគ្គលិកនេះនឹងត្រូវសើរើពិនិត្យ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ដើម្បីធានាថាគោលការណ៍ទាំងនោះពិតជាឆ្លុះបញ្ចាំងឱ្យឃើញដោយត្រឹមត្រូវនូវស្តង់ដារជ្រើសរើស និងពិនិត្យបុគ្គលិកឲ្យមានសុវត្ថិភាពចំពោះកុមារ។ គោលការណ៍ណែនាំជ្រើសរើសបុគ្គលិកដាក់បញ្ចូលនូវដំណើរការជ្រើសរើសនិងពិនិត្យបុគ្គលិកដូចខាងក្រោម ៖

- ការអះអាងប្តេជ្ញាចិត្តរបស់អង្គការយៃរចំពោះកិច្ចការពារកុមារនៅក្នុងការផ្សាយពាណិជ្ជកម្មជ្រើសរើសបុគ្គលិកទាំងអស់ និងនៅក្នុងពិពណ៌នាការងារ។
- បេក្ខជន នឹងត្រូវបានគេផ្តល់ឱ្យនូវគោលនយោបាយស្តីពីកិច្ចការពារកុមាររបស់អង្គការយៃរអូស្ត្រាលី (ឬគោលនយោបាយរបស់ដៃគូអង្គការយៃរអូស្ត្រាលី) និងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារនៅអំឡុងដំណើរការជ្រើសរើសបុគ្គលិក និងដំណើរការរៀនធ្វើការងារ។
- ការសម្ភាសន៍ទាំងអស់ត្រូវមានបញ្ចូលសំណួរស្តីពីកិច្ចការពារកុមារ។ សម្រាប់មុខតំណែងទាំងអស់ដែលមានការប្រាស្រ័យទាក់ទងជាមួយនឹងកុមារ នោះការសម្ភាសត្រូវមានសួរសំណួរដោះស្រាយបញ្ហា ដែលជាក់លាក់ទៅតាមប្រភេទនៃមុខតំណែង។
- រៀបចំទុកជាឯកសារនូវការផ្ទៀងផ្ទាត់ប្រវត្តិរូបជាមួយអ្នកធានាដោយផ្ទាល់មាត់ សម្រាប់មុខតំណែងទាំងអស់ដែលមានការប្រាស្រ័យទាក់ទងជាមួយនឹងកុមារ។
- ត្រូវស្នើសុំអ្នកដាក់ពាក្យទាំងអស់ឱ្យលាតត្រដាងប្រាប់ថាតើពួកគេធ្លាប់ត្រូវបានចោទប្រកាន់ពីបទល្មើសកេងប្រវ័ញ្ចកុមារដែរ ឬអត់។

### 4.5.1 ការពិនិត្យមើលលិខិតថ្កោលទោស

ការពិនិត្យមើលលិខិតថ្កោលទោសត្រូវធ្វើឡើងចំពោះសហការីទាំងអស់របស់អង្គការយៃរ ទោះជាពួកគេធ្វើការជាមួយនឹងកុមារ ឬក៏អត់ និងធ្វើឡើងចំពោះដៃគូដែលមានការប្រាស្រ័យទាក់ទងជាមួយនឹងកុមារផងដែរ។ ការពិនិត្យមើលលិខិតថ្កោលទោសនេះ ត្រូវធ្វើឡើងសម្រាប់ប្រទេសនីមួយៗ ដែលបេក្ខជននោះបាននិងកំពុងរស់នៅក្នុងរយៈពេល ១២ខែឬលើស នៅក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅ ហើយក៏ធ្វើឡើងសម្រាប់ប្រទេសកំណើតនៃបេក្ខជនរូបនោះផងដែរ។

នៅក្នុងកាលៈទេសៈមានកម្រិត ករណីដែលមិនអាចធ្វើបាន ឬមានហានិភ័យចំពោះអ្នកដាក់ពាក្យនៅក្នុងការស្នើសុំលិខិតថ្កោលទោសនោះ ដូច្នេះលិខិតអះអាងបញ្ជាក់ ឬលិខិតរដ្ឋបាលដែលមានតម្លៃសមមូល អាចនឹងទទួលយកជំនួសវិញបាន។ ឯកសារនេះត្រូវបញ្ចូលនូវបទចោទប្រកាន់ណាមួយ និងរយៈពេលធ្លាប់ជាប់ទោស ការកេងប្រវ័ញ្ចកុមារ ឬការប្រព្រឹត្តកំហុសធ្ងន់ផ្សេងៗទៀត។ ការផ្ទៀងផ្ទាត់ប្រវត្តិរូបជាមួយអ្នកធានាដោយម៉ត់ចត់ ក៏ត្រូវធ្វើឡើងផងដែរនៅក្នុងកាលៈទេសៈទាំងនេះ។

ការពិនិត្យមើលលិខិតថ្កោលទោសក៏នឹងត្រូវធ្វើឡើងចំពោះសហការីដែលមានស្រាប់នៃអង្គការយៃរ និងដៃគូផងដែរ ប្រសិនបើពួកគេពាក់ព័ន្ធនៅក្នុងសកម្មភាពឧក្រិដ្ឋណាមួយ ឬទទួលរងនូវនីតិវិធីដាក់ពិន័យ ឬនីតិវិធីផ្លូវច្បាប់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងការបំពានកុមារ - ដែលពួកគេត្រូវប្រាប់អង្គការយៃរអូស្ត្រាលី ឬ ដៃគូនៃអង្គការយៃរអូស្ត្រាលី - និងនៅពេលដែលពួកគេដាក់ពាក្យសុំមុខតំណែងទាំងនោះផ្ទៃក្នុង។

សហការីអង្គការយៃរ និងដៃគូត្រូវជូនដំណឹងដល់ប្រធានផ្នែកយុទ្ធសាស្ត្រ និងសេវាសម្រួលនៃអង្គការយៃរអូស្ត្រាលី (CA Director of Strategy and Enabling Services)ជាលាយលក្ខណ៍អក្សរភ្លាមៗ ប្រសិនបើបុគ្គលិកណាម្នាក់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តិ ឬត្រូវបានចាប់ខ្លួន ឬត្រូវបានថ្កោលទោសចំពោះបទល្មើសព្រហ្មទណ្ឌ ឬត្រូវបានថ្កោលទោសពាក់ព័ន្ធនឹងការរំលោភបំពានកុមារ (រួមមានការថតរូបអាសអាភាសរបស់កុមារ) ឬការកេងប្រវ័ញ្ចកុមារជាដើម។

### 4.5.2 បុគ្គលដែលបង្កហានិភ័យចំពោះកុមារ

សហការីអង្គការយៃរនឹងមិនជួល ឬប្រគល់ការងារឱ្យជនណាដែលបង្កហានិភ័យចំពោះកុមារឡើយ ហើយក៏នឹងមិនជួល ឬប្រគល់ការងារឱ្យជនណា បើលិខិតថ្កោលទោសរបស់ជននោះ (ឬលិខិតប្រកាសអះអាង/ការផ្ទៀងផ្ទាត់ប្រវត្តិរូបជាមួយអ្នកធានា នៅក្នុងករណីមិនអាចសុំលិខិតថ្កោលទោសបានទេ) មិនអាចស្នើសុំបានទេ មានដូចជាការកាត់ទោស ឬការជាប់ពន្ធនាគារជាដើម ពីបទ ៖

- បទល្មើសផ្លូវភេទមកលើកុមារ ឬមនុស្សពេញវ័យ
- បទល្មើសហិង្សាមកលើកុមារ ឬមនុស្សពេញវ័យ
- បទល្មើសរំលោភបំពានកុមារ ណាមួយ
- បទល្មើសដើរតាម/តាមដានកុមារ
- បទល្មើសកម្រិតធ្ងន់ពាក់ព័ន្ធគ្រឿងញៀន (ជួញដូរគ្រឿងញៀន ឬឱ្យថ្នាំញៀនទៅអ្នកក្នុងបន្ទុក[2] ជាកុមារ)
- បទល្មើសអំពើហិង្សារវាងដៃគូស្នេហា (ប្ដី/ប្រពន្ធ) និងហិង្សាក្នុងគ្រួសារ។

ប្រសិនបើលិខិតថ្កោលទោសរបស់បេក្ខជនមានចុះអំពីបទល្មើស ឬការជាប់ពន្ធនាគារផ្សេងទៀត នោះសហការីអង្គការយែរដែលព្យាយាមឱ្យបុគ្គលរូបនោះចូលពាក់ព័ន្ធ ដូច្នេះត្រូវធ្វើការវាយតម្លៃហានិភ័យដើម្បីសម្រេចថាតើបេក្ខជនរូបនោះបង្កឱ្យមានហានិភ័យចំពោះកុមារដែរ ឬអត់។

### 4.6 ក្រមសីលធម៌

សហការីអង្គការយែរ ដៃគូ និងភ្ញៀវទាំងអស់តម្រូវឱ្យចុះហត្ថលេខា និងប្រកាន់ខ្ជាប់ក្រមសីលធម៌ស្ដីពីកិច្ចការពារកុមារ (សូមមើល **ឧបសម្ព័ន្ធ 2**)។

កិច្ចសន្យាការងាររបស់សហការីអង្គការយែរត្រូវចែងអំពីការព្យួរការងារភ្លាមៗ ចំពោះបុគ្គលិកណាម្នាក់ ដែលស្ថិតនៅក្រោមការស៊ើបអង្កេតពីបទល្មើសនឹងគោលនយោបាយនេះ ឬ ល្មើសនឹងក្រមសីលធម៌ស្ដីពីកិច្ចការពារកុមារ។

ឯកសារស្តីពីការចូលរួមធ្វើការជាមួយគ្នារបស់អង្គការយែរអូស្ត្រាលីសម្រាប់ដៃគូ ក៏ត្រូវចែងឱ្យច្បាស់ៗផងដែរថា ការល្មើសនឹងគោលនយោបាយ និងនីតិវិធីស្ដីពីកិច្ចការពារកុមាររបស់អង្គការយែរអូស្ត្រាលី និងការល្មើសនឹងក្រមសីលធម៌ស្ដីពីកិច្ចការពារកុមារ ត្រូវចាត់ទុកថាជាកំហុសធ្ងន់ ដែលតម្រូវឱ្យមានការដាក់ទោសទណ្ឌរហូតដល់ការបញ្ឈប់ពីការងារ។

### 4.7 ការប្រើប្រាស់រូបថត រូបភាព វីដេអូ និងព័ត៌មានអំពីកុមារ

រូបថត រូបភាព វីដេអូ ឬអ្វីផ្សេងទៀតស្រដៀងគ្នាអំពីកុមារ និងព័ត៌មានផ្ទាល់ខ្លួនពាក់ព័ន្ធនឹងកុមារ ដែលអាចធ្វើឱ្យធ្លាក់ចុះការថែទាំ និងការការពារសម្រាប់កុមារ ឬចាត់ទុកថាមានលក្ខណៈកេងប្រវ័ញ្ច នឹងមិនត្រូវផ្សព្វផ្សាយជាសាធារណៈ តាមមធ្យោបាយសារព័ត៌មានណាមួយឡើយ រួមមានបណ្តាញសង្គម និងថ្នាលបច្ចេកវិទ្យាផ្ញើសារ ជាដើម។ រូបភាពអំពីកុមារមិនត្រូវអមទៅដោយព័ត៌មានលម្អិត ពាក់ព័ន្ធនឹងទីកន្លែងរស់នៅរបស់កុមារឡើយ។ រូបភាពអមដោយអត្ថបទដែលអាចឱ្យកំណត់អត្តសញ្ញាណកុមារបាន គួរដកយកចេញ។

នៅពេលថតរូប ថតវីដេអូអំពីកុមារ ឬ ប្រើប្រាស់រូបភាពរបស់កុមារនៅក្នុងគោលបំណងការងារ នោះសហការីអង្គការយែរ ដៃគូ និងភ្ញៀវទាំងអស់ត្រូវ ៖

- មុនថតរូប មុនថតវីដេអូអំពីកុមារ ត្រូវសុំការយល់ព្រមដែលមានការពន្យល់ពេញលេញពីកុមារ និងពីឪពុកម្ដាយ ឬពីអាណាព្យាបាលកុមារជាមុនសិន។
- ធានាថាការយល់ព្រមដែលមានការពន្យល់ពេញលេញនេះ មានដាក់បញ្ចូលនូវព័ត៌មានហានិភ័យច្បាស់ៗ ដែលទាក់ទិននឹងបរិបទ ជាពិសេសនៅក្នុងករណីដែលបុគ្គលមានភាពតានតឹងផ្លូវចិត្ត ឬអារម្មណ៍មិនល្អ។
- ពន្យល់ប្រាប់កុមារ និងឪពុកម្ដាយ ឬអាណាព្យាបាលថាតើរូបថត ឬ វីដេអូត្រូវប្រើប្រាស់យ៉ាងដូចម្ដេច ជាភាសាសមស្របសម្រាប់អាយុកុមារ តាមរយៈអ្នកបកប្រែ ប្រសិនបើចាំបាច់។
- យកចិត្តទុកដាក់ធានាថាប្រពៃណីតាមតំបន់ ឬ ការរឹតត្បិតនៅក្នុងការផលិតរូបភាពផ្ទាល់ខ្លួនឡើងវិញ ត្រូវបានប្រកាន់ខ្ជាប់យ៉ាងជាប់ជួន នៅមុនការថតរូប ឬការថតវីដេអូអំពីកុមារ។
- ធានាថារូបថត វីដេអូ ខ្សែភាពយន្ត និងឌីវីឌី ត្រូវបង្ហាញរូបកុមារប្រកបដោយភាពថ្លៃថ្នូរ និងការគោរព និងមិនស្ថិតនៅក្នុងរូបភាពងាយរងគ្រោះ ឬបាក់បបខ្លបខ្លាចឡើយ។
- ធានាថាកុមារស្លៀកពាក់សមរម្យ និងមិនស្ថិតនៅក្នុងជំហរ/រាងដែលបង្ហាញពីផ្លូវភេទ ឬបាក់បបខ្លបខ្លាចឡើយ។
- ធានាថារូបភាពទាំងនោះគឺជាការបង្ហាញដោយស្មោះត្រង់អំពីបរិបទ និងស្ថានភាពពិត។
- ធានាថាស្លាកសញ្ញាបិទលើហ្វាល ទិន្នន័យមេតា ឬអត្ថបទពិពណ៌នាមិនបានបង្ហាញអំពីព័ត៌មានអត្តសញ្ញាណរបស់កុមារឡើយ នៅពេលផ្ញើរូបភាពតាមប្រព័ន្ធអេឡិចត្រូនិច ឬផ្សព្វផ្សាយរូបភាពទាំងនោះនៅក្នុងទម្រង់ណាក៏ដោយ។
- សូមពន្យល់ថាការយល់ព្រមឱ្យប្រើប្រាស់រូបភាពអាចនឹងប្ដូរចិត្តមិនព្រមវិញបាន ប្រសិនបើពួកគេផ្លាស់ប្ដូរចិត្ត។

### 4.8 រាយការណ៍

សហការីអង្គការយែរ និងដៃគូ ត្រូវធានាថាបុគ្គលិកខ្លួននិងសហគមន៍ (រួមទាំងកុមារផង) ដែលអង្គការយែរអូស្ត្រាលីគ្រប់គ្រង ឬផ្ដល់ថវិកាដល់កម្មវិធី ត្រូវតែយល់ដឹងច្បាស់លាស់អំពីវិធានការត្រូវធ្វើនៅពេលមានកង្វល់ពាក់ព័ន្ធនឹងសុវត្ថិភាពកុមារ។

ដៃគូនីមួយៗរបស់អង្គការយែរអូស្ត្រាលី ត្រូវមាននីតិវិធីរាយការណ៍ជាក់លាក់សមស្របតាមប្រទេសស្ដីពីកិច្ច

[2] ពាក្យថា "ពឹងផ្អែកលើថ្នាំ" ត្រូវបានប្រើប្រាស់ដើម្បីសម្គាល់លើថ្នាំដែលត្រូវបានទទួលស្គាល់ថាជាតម្រូវការសម្រាប់ព្យាបាលប៉ុន្តែក៏មានលទ្ធភាពខ្ពស់អាចយកទៅប្រើប្រាស់មិនត្រឹមត្រូវ បំពានកម្រិតប្រើប្រាស់ ការពឹងផ្អែកលើថ្នាំ ដូច្នេះងាយនឹងត្រូវបានជួញដូរ

ការពារកុមារ ដោយគិតគូរទៅលើបរិបទតំបន់។

ការរាយការណ៍អាចធ្វើឡើងដោយបុគ្គលរូបណាក៏បានដែរ តាមរយៈ អង្គការឃែរ

http://www.care.ethicspoint.com

បទចោទប្រកាន់ណាមួយ ការដឹងឮច្បាស់លាស់ ការសង្ស័យ ឬការលាតត្រដាងប្រាប់អំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារ ឬការមិនអនុវត្តតាមគោលនយោបាយនេះ ឬក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ នឹងត្រូវរាយការណ៍ភ្លាមៗអង្គការឃែរអូស្រ្តាលី ហើយនៅក្នុងករណីតម្រូវ នោះត្រូវរាយការណ៍ទៅនាយកដ្ឋានអូស្រ្តាលីនៃផ្នែកការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី (DFAT)។

ការរាយការណ៍ទៅនាយកដ្ឋានអូស្រ្តាលីនៃផ្នែកការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី(DFAT) នឹងត្រូវធ្វើឡើងដោយប្រធានផ្នែកយុទ្ធសាស្រ្ត និងសេវាសម្រួលនៃអង្គការឃែរអូស្រ្តាលី ឬបុគ្គលដែលត្រូវបានផ្ទេរការទទួលខុសត្រូវឱ្យ យោងតាមគោលនយោបាយស្តីពីកិច្ចការពារកុមារនៃ DFAT។

### 4.8.1 ការរាយការណ៍ហេតុការណ៍

វាជាកាតព្វកិច្ចសម្រាប់បុគ្គលិកអង្គការឃែរ ឬ ដៃគូដែលបានដឹងថាមានការចោទប្រកាន់ ការដឹងឮច្បាស់លាស់ ការសង្ស័យ ឬការលាតត្រដាងប្រាប់អំពីការរំលោភបំពានកុមារ ឬការកេងប្រវ័ញ្ចកុមារ (ទោះជាកាលពីមុន ឬឥឡូវ) ដែលប្រព្រឹត្តិឡើងដោយបុគ្គលិកអង្គការឃែរ ដោយដៃគូ ឬដោយភ្ញៀវ នោះជននោះត្រូវរាយការណ៍អំពីករណីនេះភ្លាមៗមកអង្គការឃែរ។ ការរាយការណ៍ធ្វើឡើងតាមរយៈមន្ត្រីទំនាក់ទំនងផ្នែករក្សាសុវត្ថិភាពកុមារ នាយកគ្រប់គ្រងធនធានមនុស្ស នាយកប្រចាំប្រទេសនៃដៃគូនៃអង្គការឃែរអូស្រ្តាលី (នាយកប្រចាំប្រទេស) ឬប្រធានផ្នែកយុទ្ធសាស្រ្ត និងសេវាសម្រួលនៃអង្គការឃែរអូស្រ្តាលី។

ប្រធានផ្នែកយុទ្ធសាស្រ្ត និងសេវាសម្រួលនៃអង្គការឃែរអូស្រ្តាលី ឬ នាយកពាក់ព័ន្ធដែលប្រចាំតាមប្រទេស (ឬប្រតិភូរបស់នាយក/ប្រធាននោះ)នឹងធ្វើការកំណត់យន្តការតាមដានសមស្រប។ នៅក្នុងករណីដែលមានការតម្រូវឱ្យរាយការណ៍ជាកាតព្វកិច្ច នោះប្រធានផ្នែកយុទ្ធសាស្រ្ត និងសេវាសម្រួលនៃអង្គការឃែរអូស្រ្តាលី និង នាយកពាក់ព័ន្ធដែលប្រចាំតាមប្រទេស ត្រូវធានាថាការតម្រូវឱ្យរាយការណ៍ជាកាតព្វកិច្ចនេះ ត្រូវតែធ្វើវា។

ប្រសិនបើកុមារណាម្នាក់រាយការណ៍អំពីហេតុការណ៍ណាមួយ នោះកុមារ/ក្មេងជំទង់រូបនោះ ត្រូវទទួលបានការយកចិត្តទុកដាក់ និងស្តាប់ដោយផ្ចិតផ្ចង់។ នៅពេលការចោទប្រកាន់ ឬ ការលាតត្រដាងប្រាប់ត្រូវបានធ្វើឡើង នោះគួរធ្វើការឆ្លើយតបភ្លាមៗ ដោយរក្សាឱ្យកុមារ និងមនុស្សពេញវ័យដែលសុវត្ថិភាព ទទួលបាននូវការការពារពីការរំលោភបំពាន ការកេងប្រវ័ញ្ច ឬការក្លាយជាជនរងគ្រោះ។

នៅក្នុងករណីសមស្រប នោះគ្រួសាររបស់កុមាររងគ្រោះគួរទទួលបានការប្រាប់អំពីបទចោទប្រកាន់ និងវិធានការដែលបានធ្វើឡើង ហើយពួកគេគួរទទួលបានការប្រឹក្សាយោបល់ នៅក្នុងករណីសមស្រប ពាក់ព័ន្ធនឹងដំណើរការបន្តដែលត្រូវធ្វើឡើង។[3] ដំណើរការនេះនឹងត្រូវតម្រែតម្រង់ និងចង្អុលបង្ហាញដោយប្រធានផ្នែកយុទ្ធសាស្រ្ត និងសេវាសម្រួលនៃអង្គការឃែរអូស្រ្តាលី និងនាយកប្រចាំប្រទេសនៃការិយាល័យប្រចាំប្រទេស ដោយមានការប្រឹក្សាយោបល់ជាមួយនឹងអ្នកជនរងគ្រោះ។

### 4.8.2 រៀបចំជាឯកសារនូវហេតុការណ៍

បទចោទប្រកាន់អាចធ្វើឡើងដោយផ្ទាល់ តាមរយៈយន្តការផ្តល់មតិយោបល់ពីសហគមន៍បាន។

ប្រសិនបើមានការលាតត្រដាងប្រាប់បុគ្គលិកអង្គការឃែរ ឬប្រាប់ដៃគូ នោះពួកគេនឹងចងក្រងជាឯកសារពេញលេញសម្រាប់បទចោទប្រកាន់នោះ ដោយដាក់បញ្ចូលនូវពេលវេលា ទីកន្លែង និងសាក្សី ហើយធានាថាបទចោទប្រកាន់ណាមួយ និងព័ត៌មានលម្អិតនៃបទចោទប្រកាន់នោះ នឹងត្រូវរៀបចំជាឯកសារ ដោយប្រើប្រាស់ពាក្យសម្តីផ្ទាល់របស់ដើមបណ្តឹង។ ការរាយការណ៍នេះគួររៀបចំជាឯកសារភ្លាមៗ (នៅក្នុងរយៈពេល ២៤ម៉ោងនៃការលាតត្រដាងប្រាប់) ហើយអាចពាក់ព័ន្ធជាមួយនីតិវិធីផ្លូវច្បាប់ ប្រសិនបើមានការចោទប្រកាន់ណាមួយ ដោយសារតែហេតុការណ៍នោះ។

ការរាយការណ៍ទាំងអស់ គួរដាក់ជូន ប្រធានផ្នែកយុទ្ធសាស្រ្ត និងសេវាសម្រួលនៃអង្គការឃែរអូស្រ្តាលី និងនាយកប្រចាំប្រទេស។

បើហេតុការណ៍កើតឡើងនៅក្នុងប្រទេសអូស្រ្តាលី ឬមានពាក់ព័ន្ធនឹងពលរដ្ឋអូស្រ្តាលី ឬពាក់ព័ន្ធនឹងអ្នកមានសិទ្ធិរស់នៅអូស្រ្តាលី នោះប្រធានផ្នែកយុទ្ធសាស្រ្ត និងសេវាសម្រួលនៃអង្គការឃែរអូស្រ្តាលី ត្រូវប្រឹក្សាយោបល់ជាមួយនឹងអ្នកប្រឹក្សាផ្លូវច្បាប់ និងស្ថាប័នពាក់ព័ន្ធ (ឧ. ប៉ូលីសសហព័ន្ធអូស្រ្តាលី ECPAT សហធននិងរដ្ឋពាក់ព័ន្ធ ឬអង្គភាពរបស់រដ្ឋាភិបាលប្រចាំតំបន់) ដើម្បីកំណត់ដំណើរការសមស្របឆ្លើយតបទៅនឹងហេតុការណ៍ទាំងនោះ។

ប្រធានផ្នែកយុទ្ធសាស្រ្ត និងសេវាសម្រួលនៃអង្គការឃែរអូស្រ្តាលី នឹងជម្រាបជូនព័ត៌មានដល់នាយកប្រតិបត្តិ និងប្រធានក្រុមប្រឹក្សាភិបាល ឱ្យបានទាន់ពេលវេលា។

### 4.8.3 រាយការណ៍អំពីការតាមដាន

នៅក្នុងការបិទបញ្ចប់ការឆ្លើយតបទៅនឹងការលាតត្រដាងប្រាប់ ឬ ការចោទប្រកាន់ នោះបុគ្គលដែលបាន រាយ

---

[3] ត្រូវពិចារណាថាតើទង្វើអ្វីខ្លះដែលកុមារអាចនឹងទទួលរងពីគ្រួសារពួកគេ ឬពីអាជ្ញាធរមូលដ្ឋាន ឧ.តើកុមារអាចក្លាយជាជនរងគ្រោះ ជាឧក្រិដ្ឋជន ឬ មិនត្រូវបានគេរាប់រកដែរ ឬទេ។

ការណ៍ និងអ្នករួចផុតពីគ្រោះ--ប្រសិនបើពួកគេមិនមែនជាបុគ្គលតែមួយទេ-- នោះពួកគេគួរទទួលបានឱកាសផ្តល់ជាមតិយោបល់ត្រឡប់ឱ្យវិញ ទៅលើដំណើរការរាយការណ៍នេះ។

នៅក្នុងករណីដែលបុគ្គលណាម្នាក់បានរាយការណ៍ និងយល់ឃើញថាមិនមានការចាត់វិធានការគ្រប់គ្រាន់ នោះជននោះត្រូវបានលើកទឹកចិត្តឱ្យធ្វើការតាមដានដំបូង ជាមួយនឹងនាយកប្រចាំប្រទេស ឬមន្ត្រីទំនាក់ទំនងផ្នែករក្សាសុវត្ថិភាពកុមារ ចាប់តាំងពីគ្រាដំបូងទៅ។ ប្រសិនបើបុគ្គលនោះនៅតែយល់ឃើញថាមិនមានការចាត់វិធានការគ្រប់គ្រាន់ទេ នោះការតាមដានបន្តទៀតអាចនឹងប្រគល់ការចាត់ចែងទៅឱ្យប្រធានផ្នែកយុទ្ធសាស្ត្រ និងសេវាសម្រួលនៃអង្គការយែរអូស្ត្រាលី ហើយប្រសិនបើសមស្រប នឹងត្រូវប្រគល់ទៅឱ្យនាយកប្រតិបត្តិ តាមគោលនយោបាយស្តីពីការនិយាយការណ៍ពិត ឬហៅមកកាន់ខ្សែទូរស័ព្ទរបស់អង្គការយែរ។

## 4.9 ការឆ្លើយតបចំពោះការរាយការណ៍

អង្គការយែរអូស្ត្រាលីត្រូវធានាថាបានចាត់វិធានការដើម្បីគាំទ្រ និងការពារកុមារ នៅពេលមានកង្វល់កើតឡើងពាក់ព័ន្ធនឹងការរំលោភបំពាន ឬការកេងប្រវ័ញ្ចដោយថាហេតុណាមួយ។

នៅពេលឆ្លើយតបទៅនឹងការចោទប្រកាន់ នោះអង្គការយែរអូស្ត្រាលីទទួលខុសត្រូវក្នុងការធានាថា សហការី អង្គការយែរ ដៃគូ និងភ្ញៀវទទួលបានប្រព្រឹត្តិកិច្ចប្រកបដោយយុត្តិធម៌ ហើយថាសិទ្ធិរបស់បុគ្គលគ្រប់រូប ត្រូវតែទទួលបាននូវការគោរព នៅអំឡុងពេលស៊ើបអង្កេត និងដំណើរការដាក់វិន័យធរមានណាមួយ។

អង្គការយែរអូស្ត្រាលីធានាថា ជនណាម្នាក់ដែលទទួលខុសត្រូវទទួលការរាយការណ៍ ពិតជាយល់ដឹងថាតើត្រូវបំពេញភារកិច្ចរបស់ខ្លួន និងឆ្លើយតបទៅនឹងករណីទាំងនោះរបៀបណា ដោយរក្សាបាននូវសុវត្ថិភាព និងការរក្សាការសម្ងាត់។ វិធានការទាំងអស់នឹងត្រូវចាត់ឡើង តបតាមការណែនាំ ពីការវាយតម្លៃហានិភ័យលើអ្នកពាក់ព័ន្ធទាំងអស់។

ព័ត៌មាននឹងត្រូវចែករំលែកជាមួយនឹងជនទាំងឡាយណាដែលមានមុខតំណែងសមស្របប៉ុណ្ណោះ ដែលត្រូវការដឹងនូវព័ត៌មាននោះ។

ប្រធានផ្នែកយុទ្ធសាស្ត្រ និងសេវាសម្រួលនៃអង្គការយែរអូស្ត្រាលី ហើយនិងនាយកប្រចាំប្រទេសត្រូវធ្វើការវាយតម្លៃ ថាតើការរាយការណ៍នោះមានរៀបរាប់អំពីបទចោទប្រកាន់សង្ស័យរំលោភបំពានកុមារ ឬកេងប្រវ័ញ្ចកុមារដែរ ឬទេ ឬក៏ជាការមិនអនុវត្តតាមគោលនយោបាយស្តីពីកិច្ចការពារកុមារ ឬ ក្រមសីលធម៌ ដោយបុគ្គលិកអង្គការយែរ។ បើការរាយការណ៍មានរៀបរាប់ប្រាប់បទចោទប្រកាន់ នោះនឹងមានការបើកការស៊ើបអង្កេតមួយ។ តែបើគ្មានទេ នោះនឹងអនុវត្តតាមគោលនយោបាយស្តីពីបណ្តឹង។

វិធានការផ្សេងៗក្រោយការសម្រេចចិត្តនេះមានដូចជាការជូនដំណឹងដល់ម្ចាស់ជំនួយពាក់ព័ន្ធណាមួយ (រួមទាំង DFAT) ហើយនិងអាជ្ញាធរពាក់ព័ន្ធផ្សេងៗ ផងដែរ ដូចជាប៉ូលីសជាដើម។ ការជូនដំណឹងដល់ម្ចាស់ជំនួយគួរធ្វើឡើង ដោយមិនគិតពីលទ្ធផលរកឃើញនោះទេ។

ការគាំទ្រដោយផ្តល់ការប្រឹក្សាយោបល់ប្រកបដោយវិជ្ជាជីវៈ នឹងត្រូវធ្វើឡើងចំពោះសហការីពាក់ព័ន្ធទាំងអស់នៃអង្គការយែរ ។

### 4.9.1 បុគ្គលពាក់ព័ន្ធ

ជនសង្ស័យ/ជនជាប់ចោទនឹងត្រូវផ្អាក/ព្យួរពីការងារ នៅក្នុងពេលធ្វើការស៊ើបអង្កេត។ សហការីរបស់អង្គការយែរអូស្ត្រាលី ដែលផ្អាក/ព្យួរទទួលបានប្រាក់ឈ្នួលពេញ ហើយអង្គការយែរអូស្ត្រាលី នឹងអនុវត្តទៅតាមនីតិវិធីដោយត្រឹមត្រូវនៅពេលធ្វើការសម្រេច ដែលប៉ះពាល់ដល់សិទ្ធិ ឬប្រយោជន៍របស់បុគ្គល។

### 4.9.2 ការរក្សាការសម្ងាត់

ការរក្សាការសម្ងាត់មានសារសំខាន់ណាស់សម្រាប់នីតិវិធីរាយការណ៍ដែលសុវត្ថិភាព ត្រឹមត្រូវ និងប្រសិទ្ធភាព។

ការមិនអាចទទួលយកបានទេ (ហើយអាចជាការបង្ខូចកេរ្តិ៍ឈ្មោះទៀត) ចំពោះកង្វល់អំពីការរំលោភបំពានកុមារ ឬព័ត៌មានណាមួយពាក់ព័ន្ធនឹងបទចោទប្រកាន់ ឬការលាតត្រដាងប្រាប់អំពីការរំលោភបំពាន ដែលផ្សព្វផ្សាយទៅក្រៅ លើសពីការតម្រូវឱ្យរក្សាជាការសម្ងាត់នៅក្នុងដំណើរការរាយការណ៍នេះ។

អ្នកចូលរួមទាំងអស់ត្រូវដឹងពីសារសំខាន់នៃការអនុវត្តតាមបែបបទរាយការណ៍នៅពេលមានកង្វល់។ ការរក្សាការសម្ងាត់ ការពារកុមារ អ្នកជូនដំណឹង អ្នកឆ្លើយតប និងអង្គការត្រូវធានានូវដំណើរការត្រឹមត្រូវ និងសមស្រប។

### 4.9.3 ការស៊ើបអង្កេតទៅលើបទចោទប្រកាន់

ការរំលោភបំពានផ្លូវកាយ និង/ឬ ផ្លូវភេទចំពោះកុមារគឺជាបទព្រហ្មទណ្ឌ។ សហការីអង្គការយែរ ឬ ដៃគូនឹងជូនដំណឹងដល់អាជ្ញាធរនៃប្រទេសកំណើត របស់ជនជាប់ចោទបទល្មើសរំលោភបំពាន ក៏ដូចជាប្រទេសម្ចាស់ផ្ទះ នៅពេលមានសំអាងសមស្រប ពាក់ព័ន្ធនឹងការរាយការណ៍អំពីបទរំលោភបំពាន ដោយពិចារណាជាចម្បងលើសុវត្ថិភាពសម្រាប់ជនរងគ្រោះ--អ្នករួចផុតពីគ្រោះ។

ប្រសិនបើមានស្ថាប័នខាងក្រៅពាក់ព័ន្ធនឹងបញ្ហានោះដែរ ដូចជាប៉ូលីស ឬអង្គភាពមានសមត្ថកិច្ចជាដើម នោះសហការីអង្គការយែរគួរសួរសមត្ថកិច្ចទាំងនោះថាតើសមត្ថកិច្ចចង់ឱ្យពួកគេអនុវត្តនីតិវិធីរបស់អង្គការពួកគេជាមុន នៅមុនពួកគេធ្វើការស៊ើបអង្កេតផ្ទៃក្នុងរបស់ពួកគេដែរ ឬទេ។ ប្រសិនបើការណែនាំរបស់សមត្ថកិច្ចខាងក្រៅវាត្រូវគ្នាជាមួយនឹងបំណងនៃគោលនយោបាយនេះ និងច្បាប់ដែរនោះ នោះការស៊ើបអង្កេតណាមួយដែលធ្វើឡើង

ដោយសហការីអង្គការយែរ ត្រូវស្ថិតនៅក្រោមការណែនាំទាំងនោះវិញ។

បទចោទប្រកាន់ដែលធ្វើឡើងនៅក្រៅប្រទេស ចាំបាច់ត្រូវពិនិត្យមើលលើលិខិតបទដ្ឋានគតិយុត្តិប្រទេសក្រៅនោះ ឬនីតិវិធីផ្ទៃក្នុងដើម្បីស៊ើបអង្កេត និងដោះស្រាយបទចោទប្រកាន់នោះ។[4]

ការស៊ើបអង្កេតផ្ទៃក្នុងត្រូវតែជាដំណើរការមួយដែលរក្សាការសម្ងាត់ ម៉ត់ចត់ មិនលម្អៀង និងទាន់ពេលវេលា។ ការស៊ើបអង្កេតអាចតម្រូវឱ្យមានការសម្ភាសជាមួយសាក្សី និងបុគ្គលផ្សេងៗឱ្យបានសមរម្យ ការប្រមូលព័ត៌មានអំពីសកម្មភាពប្រព្រឹត្តិដែលរងការចោទប្រកាន់ ការប្រមូលឯកសារ ឬនីតិវិធីផ្សេងៗឱ្យបានសមស្រប ស្របតាមគោលការណ៍ស៊ើបអង្កេត។

ជនជាប់ចោទពីបទប្រព្រឹត្តិល្មើសគោលនយោបាយនេះ ត្រូវបានគេប្រាប់ឱ្យដឹងអំពីបទចោទប្រកាន់មកលើខ្លួនដោយលម្អិតគ្រប់គ្រាន់ និងត្រូវទុកឱកាសឱ្យសមស្របដើម្បីឆ្លើយតបនឹងការចោទប្រកាន់នីមួយៗ។ អង្គការយែរអូស្ត្រាលី នឹងធ្វើការកំណត់ថាតើនៅពេលណាការស៊ើបអង្កេតនឹងត្រូវបញ្ចប់។

នៅក្នុងករណីខ្លះ ការស៊ើបអង្កេតខាងក្រៅអាចនឹងត្រូវធ្វើឡើង តាមការសម្រេចដោយប្រធានផ្នែកយុទ្ធសាស្ត្រ និងសេវាសម្រួលនៃអង្គការយែរអូស្ត្រាលី ឬដោយនាយកប្រចាំប្រទេស។ ការសម្រេចនេះគឺផ្អែកលើកត្តាមួយចំនួនដូចជា ភាពធ្ងន់ធ្ងរ ឬភាពស្មុគស្មាញនៃការចោទប្រកាន់ មានបុគ្គលិកជំនាញធ្វើការស៊ើបអង្កេត និងលទ្ធភាពនៃការចាត់វិធានការតាមផ្លូវច្បាប់។

### 4.9.4 **ការកត់កំណត់ហេតុការស៊ើបអង្កេត**

ផ្អែកលើព័ត៌មានប្រមូលបាន ដែលជាផ្នែកមួយនៃការស៊ើបអង្កេត នោះអ្នកស៊ើបអង្កេតនឹងរៀបចំរបាយការណ៍ពេញលេញ ដោយមានចុះនូវលទ្ធផលរកឃើញ ក៏ដូចជាភស្តុតាងបញ្ជាក់ចំពោះលទ្ធផលនោះ។ ព័ត៌មានប្រមូលបាន ដែលជាផ្នែកមួយការស៊ើបអង្កេតគួរភ្ជាប់ជាមួយនឹងរបាយការណ៍ស៊ើបអង្កេត ហើយត្រូវរក្សាទុកនៅទីកន្លែងសមស្រប ដើម្បីរក្សាការសម្ងាត់។

### 4.9.5 **ការរាយការណ៍អំពីលទ្ធផលរកឃើញ**

បន្ទាប់ពីការបិទបញ្ចប់ការស៊ើបអង្កេត និងការរៀបចំរបាយការណ៍ នោះការកំណត់មួយនឹងត្រូវធ្វើឡើងដោយប្រធានផ្នែកយុទ្ធសាស្ត្រ និងសេវាសម្រួលនៃអង្គការយែរអូស្ត្រាលី និងដោយនាយកប្រចាំប្រទេស ថាតើបទចោទប្រកាន់មកលើបុគ្គលិកអង្គការយែរមានភស្តុតាងគ្រប់គ្រាន ឬគ្មានភស្តុតាងគ្រប់គ្រាន់ដែរឬទេ ។ ប្រសិនបើកម្មវត្ថុមានភស្តុតាងគ្រប់គ្រាន់ នោះពួកគេ ឬអ្នកតំណាងពួកគេនឹងធ្វើការកំណត់ទោសទណ្ឌវិន័យ ដែលនឹងត្រូវសម្រេចដោយថ្នាក់គ្រប់គ្រង និងអង្គភាពគ្រប់គ្រងពាក់ព័ន្ធ ហើយដែលបុគ្គលិកអង្គការយែរត្រូវទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួន។ វិធានការវិន័យនេះអាចបញ្ចូលនូវទោសទណ្ឌមួយចំនួនទៀត រួមទាំងការរំលាយកិច្ចសន្យាការងារផងដែរ ដោយយោងលើភាពធ្ងន់ធ្ងរនៃអំពើល្មើស។

### 4.9.6 **ការស្តីបន្ទោស**

សហការីអង្គការយែរមិនអត់ឱនដាច់ខាតចំពោះទម្រង់នៃការបង្ខិតបង្ខំ ការបំភ័យ ការស្តីបន្ទោស ឬការសងសឹកមកលើបុគ្គលដែលរាយការណ៍អំពីករណីនៃការរំលោភបំពាន ឬការកេងប្រវ័ញ្ច ឬដែលផ្តល់ព័ត៌មានណាមួយ ឬការជួយផ្សេងៗ នៅក្នុងការស៊ើបអង្កេត ដូចដែលមានចែងនៅក្នុងគោលនយោបាយស្តីពីការនិយាយការណ៍ពិតរបស់អង្គការយែរអូស្ត្រាលី។

## 5. **គោលនយោបាយពាក់ព័ន្ធ និងនីតិវិធីនានា**

- ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ (ឧបសម្ព័ន្ធ 2)
- គោលនយោបាយស្តីពីការរក្សាសុវត្ថិភាពកុមារ នៃអង្គការយែរអន្តរជាតិ (2020)
- សៀវភៅគោលនយោបាយស្តីពីធនធានមនុស្ស នៃអង្គការយែរអូស្ត្រាលី
- គោលនយោបាយស្តីពីសុខភាព និងសុវត្ថិភាពនៃអង្គការយែរអូស្ត្រាលី
- គោលនយោបាយស្តីពីការទប់ស្កាត់ការបៀតបៀន និងការរើសអើង នៃអង្គការយែរអូស្ត្រាលី
- គោលនយោបាយស្តីពីការការពារការនិយាយការណ៍ពិតនៃអង្គការយែរអូស្ត្រាលី
- គោលនយោបាយស្តីពីបទឆបោក និងអំពើពុករលួយ នៃអង្គការយែរអន្តរជាតិ
- គោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យ នៃអង្គការយែរអូស្ត្រាលី
- ពិធីសារស៊ើបអង្កេតបទល្មើស នៃអង្គការយែរអូស្ត្រាលី
- កំណត់សម្គាល់ស្តីពីការណែនាំការពារកុមារនៃអង្គការយែរអូស្ត្រាលី - ភាពជាដៃគូជាមួយនឹងអង្គការផ្សេងៗ (ខែធ្នូ ឆ្នាំ 2020)
- កំណត់សម្គាល់ស្តីពីការណែនាំការពារកុមារ នៃអង្គការយែរអូស្ត្រាលី - ការចូលរួមពីសេវាខាងក្រៅ (ខែមិនា ឆ្នាំ2020)
- កំណត់សម្គាល់ស្តីពីការណែនាំការពារកុមារនៃអង្គការយែរអូស្ត្រាលី - ការជ្រើសរើស និងការសម្រិតសម្រាំងបុគ្គលិក (ខែធ្នូ ឆ្នាំ 2020)
- របាយការណ៍ស្តីពីកង្វល់បៀតបៀនផ្លូវភេទ ការកេងប្រវ័ញ្ច ការរំលោភបំពាន និងការពារកុមារ នៃអង្គការយែរអូស្ត្រាលី

[4] ត្រូវធ្វើការពិចារណាថាតើអាជ្ញាធរមូលដ្ឋាននឹងធ្វើយ៉ាងដូចម្តេចចំពោះជនដៃដល់ (ឧ.ធ្វើទណ្ឌកម្ម ទោសប្រហារជីវិត ឬប្រព័ន្ធយុត្តិធម៌ពុករលួយ) ក៏ដូចជាចំពោះកុមារ (ឧ. តើកុមារនឹងក្លាយជាជនរងគ្រោះ ជាឧក្រិដ្ឋជន ឬត្រូវបានគេបង្ខំឱ្យពិនិត្យសុខភាពដែរឬទេ)។

- ការរាយការណ៍ & នីតិវិធីស៊ើបអង្កេត នៃអង្គការយៃរអូស្ត្រាលី ស្តីពីការបៀតបៀនផ្លូវភេទ ការកេងប្រវ័ញ្ច ការរំលោភបំពាន និងកិច្ចការពារកុមារ (ខែវិច្ឆកា ឆ្នាំ2021)
- គោលនយោបាយស្តីពីបណ្តឹងនៃអង្គការយៃរអូស្ត្រាលី

## 6. ឯកសារគាំទ្រ និងឯកសារយោង

### 6.1 ច្បាប់

- ច្បាប់ស្តីពីការប្រឆាំងការរើសអើងនៃសហធនអូស្ត្រាលី
- ច្បាប់ស្តីពីការងារសមរម្យ (Cth)
- ធម្មនុញ្ញស្តីពីសិទ្ធិមនុស្ស (Vic and ACT)
- ច្បាប់ស្តីពីសុខភាព និង សុវត្ថិភាពការងារ (ACT)
- ច្បាប់ស្តីពីសុខភាព និងសុត្ថិភាពមុខរបរ (Vic)
- ក្រមព្រហ្មទណ្ឌនៃរដ្ឋសហធន
- បទល្មើសព្រហ្មទណ្ឌ (Vic) [ដូចជា : ការសម្លុត ការបញ្ចុះបញ្ចូលដើម្បីបានបៀតបៀនផ្លូវភេទ ការដើរតាម ការចាប់រំលោភព បទល្មើសផ្លូវភេទ ហិង្សាគ្រួសារ ការថតរូបអាសអាភាសកុមារ]
- ច្បាប់ស្តីពីហិង្សាលើខ្លួនប្រាណ (ACT) [ការដើរតាម, ហិង្សាគ្រួសារ]
- បទល្មើសព្រហ្មទណ្ឌ (ACT) [រួមមាន : បញ្ចុះបញ្ចូលរួមភេទ ការដើរតាម សកម្មភាពប៉ះពាល់ផ្លូវភេទ អំពើអាសអាភាស]
- បទប្បញ្ញត្តិព្រហ្មទណ្ឌ (ការរំលោភបំពានកុមារជាក់ស្តែង) (Vic)
- បទប្បញ្ញត្តិព្រហ្មទណ្ឌ (ការថតរូបអាសអាភាសកុមារ) (Vic)
- បទប្បញ្ញត្តិព្រហ្មទណ្ឌ (បទល្មើសនៅក្រៅដែនដី) (Vic)

### 6.2 ឯកសាររបស់អង្គការយៃរអូស្ត្រាលី និងអង្គការយៃរអន្តរជាតិ

- តម្លៃ និងក្រមសីលធម៌របស់អង្គការយៃរអូស្ត្រាលី
- គោលនយោបាយស្តីពីការរក្សាសុវត្ថិភាពកុមាររបស់អង្គការយៃរអន្តរជាតិ
- គោលនយោបាយស្តីពីការនិយាយការណ៍ពិតរបស់អង្គការយៃរយៃរអូស្ត្រាលី

### 6.3 ឧបសម្ព័ន្ធ

1. លក្ខខណ្ឌតម្រូវឱ្យមានកិច្ចការពារកុមារចំពោះសហការីអង្គការយៃរ
2. ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ
3. ការទទួលស្គាល់ចំពោះក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ

## 7. ម្ចាស់កម្មសិទ្ធិលើគោលនយោបាយ

នាយកប្រតិបត្តិនៃអង្គការយៃរអូស្ត្រាលី ជូសមុខឱ្យក្រុមប្រឹក្សាភិបាល

## 8. ការអនុវត្ត និង ការទំនាក់ទំនង

គោលនយោបាយនេះ នឹងធ្វើការផ្សព្វផ្សាយនៅលើថ្នាលបច្ចេកវិទ្យា (វែបសាយ ផេជ) របស់អង្គការយៃរ។ គោលនយោបាយនេះក៏នឹងត្រូវផ្សព្វផ្សាយទៅខាងក្រៅផងដែរ តាមរយៈអង្គការយៃរអូស្ត្រាលី និងនៅលើវែបសាយរបស់ដៃគូនៃអង្គការយៃរអូស្ត្រាលី។

សហការីរបស់អង្គការយៃរ និងដៃគូទាំងអស់របស់ខ្លួននឹងត្រូវបានគេផ្តល់ឱ្យនូវសេចក្តីចម្លងមួយច្បាប់ (ឯកសារកូពី) នៃគោលនយោបាយនេះ (ឬចូលប្រើប្រាស់វា) ហើយតម្រូវឱ្យយល់ព្រម និងចុះហត្ថលេខាលើក្រមសីលធម៌នោះ។

## 9. សេចក្តីលម្អិតនៃគោលនយោបាយ

- កាលបរិច្ឆេទនៃគោលនយោបាយ ៖ ខែកក្កដា ឆ្នាំ 2022
- ប្រវត្តិការកែប្រែគោលនយោបាយ : កំណែលើកទី 1 (កែសម្រួលសំខាន់ៗទៅលើគោលនយោបាយលើកមុនស្តីពីកិច្ចការពារកុមារ 2021-2022)
- កាលវិភាគសម្រាប់សើរើពិនិត្យមើលគោលនយោបាយ ៖ អង្គការយៃរអូស្ត្រាលី នឹង ការសើរើពិនិត្យមើលគោលនយោបាយ រៀងរាល់បីឆ្នាំ ឬឆាប់ជាងនេះ ប្រសិនបើមានដីកា ដូចជាតាមការតម្រូវដោយច្បាប់ ដែលបានធ្វើវិសោធនកម្ម ការផ្លាស់ប្តូរបរិបទ ឬការលើកកម្ពស់ជាប្រចាំ ដែលកើតចេញពីការគ្រប់គ្រងហេតុការណ៍ និងការតាមដាន។ គោលនយោបាយនេះ ត្រូវសុំការឯកភាពពីក្រុមប្រឹក្សាភិបាល។

## 10. និយមន័យ

**កុមារ** ត្រូវបានកំណត់និយមន័យថាជាមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ។

**ការរំលោភបំពានកុមារ** គឺជាការរំលោភបំពានដែលធ្វើឱ្យមានគ្រោះថ្នាក់ជាក់ស្តែង ឬជាយថាហេតុ ទៅដល់សុខភាព ការអភិវឌ្ឍ ឬភាពថ្លៃថ្នូររបស់កុមារនៅក្នុងបរិបទដែលមានភាពជាប់ទាក់ទងគ្នារវាងការទទួលខុសត្រូវ ទំនុកចិត្ត អំណាច។ ចំណុចនេះមានដូចជាការរំលោភបំពានផ្លូវកាយ ការទុកចោលមិនអើពើ ការរំលោភបំពានផ្លូវអារម្មណ៍ ការរំលោភបំពានផ្លូវភេទ ឬ ការធ្វើបាប។ ការរំលោភបំពានអាចប្រព្រឹត្តិឡើងដោយមនុស្សពេញវ័យ ក្មេង

ជំទង់ ឬ កុមារផ្សេងទៀត។

**ការកេងប្រវ័ញ្ចកុមារ** (មានពាក់ព័ន្ធនឹងសកម្មភាពមួយ ឬច្រើនដូចខាងក្រោម) ៖

- ប្រព្រឹត្តិសកម្មភាពណាមួយ ឬច្រើនដែលជាការរំលោភបំពានមកលើកុមារ ឬបញ្ចុះបញ្ចូលកុមារដើម្បីបានរូបភេទ
- បង្ខំឱ្យជនណាម្នាក់ផ្សេងទៀតប្រព្រឹត្តិសកម្មភាពណាមួយ ឬច្រើនដែលជាការរំលោភបំពានមកលើ កុមារ ឬបញ្ចុះបញ្ចូលកុមារដើម្បីបានរូបភេទ
- កាន់កាប់ គ្រប់គ្រង ផលិត ចែកផ្សាយ ទទួល ឬផ្ញើឯកសារអំពីការកេងប្រវ័ញ្ចកុមារ។

**ពលកម្មកុមារ** គឺជាការងារដែលធ្វើឱ្យកុមារបាត់បង់នូវកុមារភាពរបស់ពួកគេ បាត់បង់នូវសក្តានុពល និងភាពថ្លៃថ្នូររបស់ពួកគេ ហើយដែលនេះវាបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ។ ពលកម្មនេះសំដៅដល់ការងារទាំងឡាយណា ដែល ៖

- មានគ្រោះថ្នាក់ ឬធ្វើឱ្យមានជំងឺខាងផ្លូវចិត្ត ផ្លូវកាយ ផ្លូវសង្គម ឬផ្លូវសិលធម៌ចំពោះកុមារ និង/ឬ
- ប៉ះពាល់ដល់ការសិក្សា ដោយ ៖ ធ្វើឱ្យកុមារបាត់បង់ឱកាសចូលរៀន ធ្វើឱ្យពួកគេឈប់រៀននៅវ័យក្មេង ឬធ្វើឱ្យកុមាររៀនផង និងធ្វើការងារធ្ងន់ៗយ៉ាងច្រើនយ៉ាងលំបាកលំបិន។

**ការរំលោភបំពានផ្លូវភេទលើកុមារ** គឺជាទម្រង់មួយនៃសកម្មភាពផ្លូវភេទទៅលើកុមារ។ ជាក់ស្តែង ឃើញមានសកម្មភាពរវាងកុមារ ជាមួយនឹងមនុស្សពេញវ័យ ឬជាមួយនឹងកុមារផ្សេងទៀត ដោយមើលលើអាយុ និងការអភិវឌ្ឍរបស់ពួកគេ ឃើញមានភាពទាក់ទងគ្នារវាងការទទួលខុសត្រូវ ទំនុកចិត្ត ឬអំណាច ដែលសកម្មភាពនោះធ្វើឡើងក្នុងគោលបំណងបំពេញ ឬតម្រូវចិត្តរបស់បុគ្គលម្ខាងទៀត។

ចំណុចនេះរាប់បញ្ចូលទាំងសកម្មភាពដែលមានការទាក់ទងគ្នា ឬគ្មានការទាក់ទងគ្នា ការល្បួង ឬ ការលួងកុមារឱ្យចូលពាក់ព័ន្ធនៅក្នុងសកម្មភាពផ្លូវភេទ ប្រើប្រាស់កុមារនៅក្នុងពេស្យាកម្ម ឬសកម្មភាពផ្លូវភេទនានា ឬបង្ហាញរូបកុមារនៅលើប្រព័ន្ធអនឡាញមានលក្ខណៈជាការកេងប្រវ័ញ្ចផ្លូវភេទ ឬ កុមារនៅក្នុងការសម្តែងអាសអាភាស និងថតនៅក្នុងរូបភាពអាសអាភាស ឬកេងប្រវ័ញ្ចផ្លូវភេទលើរូបភាពរបស់កុមារ --ដោយមិនកំណត់ត្រឹមប៉ុណ្ណឹងទេ។

**ការកេងប្រវ័ញ្ចផ្លូវភេទកុមារ** គឺជាការរំលោភបំពានជាក់ស្តែង ឬដោយប៉ុនប៉ង ខណៈដែលកុមារស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ អំណាចខុសគ្នា ឬការទុកចិត្ត ដើម្បីបំណងផ្លូវភេទ។ សកម្មភាពនោះអាចពាក់ព័ន្ធនឹងការ កាន់កាប់ ការគ្រប់គ្រង ការផលិត ការចែកផ្សាយ ឬការទទួល ឬការផ្ញើឯកសារអំពីការកេងប្រវ័ញ្ចលើកុមារ រួមមានរូបថតអាសអាភាសរបស់កុមារ ឬការជ្រើសរើសកុមារធ្វើការងារ ការដឹកជញ្ជូនកុមារ ឬការទទួលកុមារដើម្បីការកេងប្រវ័ញ្ច តាមរយៈការគំរាមកំហែង ការបង្ខិតបង្ខំ ឬការល្បួងលួង។ បុគ្គលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារអាចស្វែងរកផលប្រយោជន៍ជាលុយកាក់ ផលប្រយោជន៍ក្នុងសង្គម ឬផលប្រយោជន៍ក្នុងតំណែងនយោបាយ ពីការកេងប្រវ័ញ្ចផ្លូវភេទកុមារនេះ។

**ការទាក់ទងជាមួយកុមារ** សម្តៅដល់តួនាទី ឬសកម្មភាពទាំងឡាយណា ដែលពាក់ព័ន្ធ ឬអាចនឹងពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងកុមារ ដោយសារតែមុខតំណែង ឬដោយសារតែបរិយាកាសធ្វើការងារ ឬដោយសារតែការចូលប្រើប្រាស់ ឬការកាន់កាប់ព័ត៌មានរបស់កុមារ។ ប្រធានផ្នែកជ្រើសរើសបុគ្គលិក ដោយមានការគាំទ្រពីមន្ត្រីទំនាក់ទំនងផ្នែករក្សាសុវត្ថិភាពកុមារ នៅក្នុងករណីចាំបាច់ ត្រូវទទួលខុសត្រូវនៅក្នុងការកំណត់ថាតើមុខតំណែងទាំងនោះមានជាប់ទាក់ទងជាមួយនឹងកុមារដែរ ឬអត់។

**ការរំលោភបំពានផ្លូវអារម្មណ៍** គឺជាអំពើមិនសមរម្យតាមរយៈពាក្យសម្តី ឬកាយវិកាប្រព្រឹត្តិឡើងដោយអ្នកមើលថែ ឬដោយឪពុកម្តាយកុមារមកលើកុមារ ឬការខានមិនបានផ្តល់ឱ្យកុមារនូវការមើលថែផ្លូវអារម្មណ៍ និងភាពកក់ក្តៅផ្លូវចិត្តគ្រប់គ្រាន់។ អំពើនេះផ្តល់នូវលទ្ធភាពខ្ពស់ណាស់ដល់ការធ្វើឱ្យខូចខាតនូវអារម្មណ៍ជឿជាក់លើខ្លួនឯង សុខភាពផ្លូវចិត្ត ឬសមត្ថភាពក្នុងសង្គម។

**ការបញ្ចុះបញ្ចូលដើម្បីបៀតបៀនផ្លូវភេទ** សម្តៅដល់ការធ្វើអំពើទាំងឡាយណាដែលបង្កឱ្យមានភាពងាយស្រួលចំពោះបុគ្គលណាម្នាក់ដើម្បីពាក់ព័ន្ធនៅក្នុងការបៀតបៀនផ្លូវភេទ ការកេងប្រវ័ញ្ច ឬការរំលោភបំពានដល់បុគ្គលម្ខាងទៀត។ ការបញ្ចុះបញ្ចូលនេះមានពាក់ព័ន្ធនឹងការប្រើប្រាស់នូវតិចនិចជាច្រើន យ៉ាងប៉ិនប្រសព្វ និងគ្រប់គ្រងលើភាគីម្ខាងទៀត ដែលជាកម្មវត្ថុរងគ្រោះ និងគ្រប់គ្រងលើបុគ្គល និងស្ថានការនៅជុំវិញទៀតផង ដើម្បីធ្វើឱ្យមានទំនុកចិត្ត ឬធ្វើឱ្យទៅជាធម្មតានូវសកម្មភាពរំលោភបំពានផ្លូវភេទដែលមានការឈឺចាប់នោះ នៅក្នុងគោលបំណងសម្របសម្រួលការកេងប្រវ័ញ្ច និង/ឬហាមឃាត់ការលាតត្រដាងប្រាប់គេឯងអំពីអំពើល្មើសរបស់ខ្លួន ឬផ្តល់ឱ្យនូវអត្ថប្រយោជន៍ដើម្បីការពារនូវហេតុផលរបស់ខ្លួន ឬបដិសេធទង្វើរបស់ខ្លួនទាំងស្រុង។ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ជាច្រើនប្រភេទអាចនឹងត្រូវបានប្រើប្រាស់ដើម្បីធ្វើសកម្មភាពបញ្ចុះបញ្ចូលរួមភេទនេះ។

**ការធ្វើបាបកុមារ** សម្តៅដល់ការដាក់វិន័យ ឬការកែកំហុសចំពោះកុមារ ដោយវិធីមិនសមហេតុផល មិនសមរម្យ ឬមិនត្រឹមត្រូវ ដោយទាមទារច្រើនជ្រុល និង/ឬ គ្មានន័យ *(ឱ្យកុមារធ្វើនេះធ្វើនោះ)* ឬបង្ខិតបង្ខំទទឹងទទែងមកលើកុមារ និង/ឬការស្តីប្រដៅដោយពាក្យសម្តីអសុរស ឬគ្មានហេតុផល អសីលធម៌ មិនសរម្យចំពោះកុមារ ឬការធ្វើ ទង្វើដោយកម្លាំងកាយមិនសមរម្យមកលើកុមារ។

**ការមិនអើពើ** គឺជាការមិនបានបំពេញតួនាទីរបស់ឪពុកម្តាយ ឬអ្នកថែទាំ នៅក្នុងការផ្តល់ឱ្យកុមារ (ករណីដែលពួកគេមានតួនាទីត្រូវបំពេញដូច្នេះ) នូវលក្ខខណ្ឌធំលូតលាស់ ដែលអាចទទួលយកបានតាមវប្បធម៌នៅក្នុងតំបន់ដែលកុមាររស់នៅ ដែលលក្ខខណ្ឌនេះវាសំខាន់សម្រាប់ការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្ត និងសុខុមាលភាពកុមារខ្លាំងណាស់។

**ការរំលោភបំពានផ្លូវកាយ** សម្តៅដល់ការធ្វើឱ្យឈឺចាប់ដល់រាងកាយដែលមិនមែនជាគ្រោះថ្នាក់ ការគំរាមកំហែង ឬហានិភ័យធ្វើឱ្យឈឺចាប់ដល់រាងកាយកុមារ ដោយមនុស្សពេញវ័យ។ ការរំលោភបំពានផ្លូវកាយអាចធ្វើឡើងដោយចេតនា ឬអចេតនា ដោយសារតែការដាក់ទណ្ឌកម្ម ឬការដាក់វិន័យហួសហេតុ។ ការរំលោភបំពាននេះអាចជាអំពើប្រព្រឹត្តិតែម្តង ឬច្រើនដងមិនរាងចាល ហើយមិនបានបន្សល់ទុកស្លាកស្នាមមើលឃើញដោយភ្នែក ឬការរង

របួសទេ។

**មានភស្តុតាងគ្រប់គ្រាន់** មានន័យថាបន្ទាប់ពីការស៊ើបអង្កេតលើបទចោទប្រកាន់មួយ នោះគេឃើញមានភស្តុតាងគាំទ្រលើបទចោទប្រកាន់នោះ។

**គ្មានភស្តុតាងគ្រប់គ្រាន់** មានន័យថាបន្ទាប់ពីការស៊ើបអង្កេតលើបទចោទប្រកាន់មួយ នោះគេឃើញគ្មានភស្តុតាងគាំទ្រលើបទចោទប្រកាន់នោះទេ។

**ការធ្វើការជាមួយកុមារ**មានន័យថាជាការចូលពាក់ព័ន្ធធ្វើសកម្មភាពជាមួយកុមារ ដែលនៅក្នុងករណីនេះការទាក់ទងជាមួយកុមារត្រូវបានរំពឹងទុកដោយសមហេតុផលថាជាសកម្មភាពធម្មតា ហើយការទាក់ទងនោះវាមិនមែនមិនសំខាន់ចំពោះសកម្មភាពធ្វើការងារនោះទេ។ ការធ្វើការងារអាចជាការងារស្ម័គ្រចិត្ត និងការងារដោយមិនបានប្រាក់ឈ្នួល។

- **ឧបសម្ព័ន្ធ** 1

## លក្ខខណ្ឌតម្រូវឱ្យមានកិច្ចការពារកុមារ

ដំណើរការគ្រប់គ្រងហានិភ័យនៃគម្រោង ត្រូវដាក់បញ្ចូលកុមារ ការរក្សាសុវត្ថិភាពកុមារ និងការវាយតម្លៃការការពារ ហើយចំណុចខាងក្រោមទាំងនេះត្រូវអនុវត្ត (កែសម្រួលតាមបរិបទតំបន់ ដោយសហការជាមួយនឹងអ្នកពាក់ព័ន្ធក្នុងតំបន់ឱ្យបានសមស្រប) ៖

- គោលនយោបាយស្តីពីកិច្ចការពារកុមារដែលអនុវត្ត ឬដែលស៊ីចង្វាក់គ្នាជាមួយនឹង ស្តង់ដាររបស់អង្គការយៃរអូស្ត្រាលី ដែលមានចែងនៅក្នុងគោលនយោបាយស្តីពីកិច្ចការពារកុមាររបស់អង្គការយៃរអូស្ត្រាលី[5]
- ការជ្រើសរើសបុគ្គលិកដែលសុវត្ថិភាពចំពោះកុមារ និង ដំណើរការពិនិត្យបុគ្គលិក រួមមានដូចជាការពិនិត្យមើលលិខិតថ្កោលទោស ដែលស្របគ្នាជាមួយនឹងស្តង់ដាររបស់អង្គការយៃរអូស្ត្រាលី ដែលមានចែងនៅក្នុងគោលនយោបាយស្តីពីកិច្ចការពារកុមាររបស់អង្គការយៃរអូស្ត្រាលី នៅមុនការចូលរួមការងារ សំណួរសម្ភាសន៍ផ្តោតលើគោលដៅ និងការផ្ទៀងផ្ទាត់ប្រវត្តិរូបជាមួយអ្នកធានាដោយផ្ទាល់មាត់ សម្រាប់បុគ្គលិកទាំងអស់ (រួមទាំងអ្នកស្ម័គ្រចិត្ត និងអ្នកបាត់ការ ) ដែលត្រូវការធ្វើការជាមួយ កុមារ
- យន្តការច្បាស់លាស់ស្តីពីការផ្តល់មតិយោបល់ពីសហគមន៍ដែលត្រូវកែសម្រួលតាមបរិបទមូលដ្ឋាន និងអាចផ្តល់ជាយោបល់ដោយ អ្នកចូលរួមក្នុងកម្មវិធីទាំងអស់
- នីតិវិធីគ្រប់គ្រងបណ្តឹងការពារកុមារដែលបានរៀបចំជាឯកសារ
- ធ្វើការបណ្តុះបណ្តាលអំពីកិច្ចការពារកុមារដល់បុគ្គលិកពាក់ព័ន្ធ
- ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារដែលត្រូវតែចុះហត្ថលេខាដោយអ្នកពាក់ព័ន្ធទាំងអស់ (សហការីអង្គការយៃរ និងដៃគូ) ហើយនិងគៀរ
- ការចែងនៅក្នុងកិច្ចសន្យាការងារទាំងអស់ ដែលអង្គការមានសិទ្ធិព្យួរបាន (ដោយមានប្រាក់ឈ្នួល ឬគ្មានប្រាក់ឈ្នួល) ឬការផ្ទេរបុគ្គលិកឱ្យធ្វើការងារផ្សេង ប្រសិនបើស្ថិតនៅក្រោមការស៊ើបអង្កេតពីបទល្មើសនឹងគោលនយោបាយស្តីពីកិច្ចការពារកុមារ ឬល្មើសនឹងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ ហើយនិងការចែងអំពីការចាត់វិធានការដាក់វិន័យរដ្ឋបាល រាប់ចាប់ពីការស្តីបន្ទោស រហូតដល់ការបណ្តេញចេញពីការងារ ប្រសិនបើបុគ្គលិកត្រូវបានរកឃើញថាបានប្រព្រឹត្តិល្មើសនឹងគោលនយោបាយស្តីពីកិច្ចការពារកុមារ ឬល្មើសនឹងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ
- រៀបចំជាឯកសារសម្រាប់យន្តការអនុលោមគោលនយោបាយ ដូចជាទណ្ឌកម្មចែងជាក់លាក់ចំពោះការប្រព្រឹត្តិល្មើស។
- យន្តការរាយការណ៍ នៅក្នុងករណីដែលប្រធានផ្នែកយុទ្ធសាស្ត្រ និងសេវាសម្រួល នៃអង្គការយៃរអូស្ត្រាលីទទួលបានការជូនដំណឹងភ្លាមៗជាលាយលក្ខណ៍អក្សរប្រសិនបើមានបុគ្គលិកណាម្នាក់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តិ ឬត្រូវបានចាប់ខ្លួន ឬត្រូវបានថ្កោលទោសពីបទល្មើសព្រហ្មទណ្ឌ ពាក់ព័ន្ធនឹង ការរំលោភបំពានកុមារ ឬការថតរូបអាសអាភាសកុមារ។

[5] ចំណុចនេះមានពាក់ព័ន្ធនឹងការិយាល័យប្រចាំប្រទេស ដែលបានយកមកប្រើ និងបានឯកភាពទៅលើ គោលនយោបាយស្តីពីកិច្ចគាំពារកុមារនៃអង្គការយៃរអូស្ត្រាលី

- **ឧបសម្ព័ន្ធ** 2

## ក្រមសីលធម៌ស្ដីពីកិច្ចការពារកុមារ

ការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារមិនអាចទទួលយកបានទេ ហើយសហការីអង្គការយៃរ និងដៃគូ[6] ប្ដេជ្ញាចិត្តអនុវត្ត តម្កល់ និងលើកកម្ពស់ស្តង់ដារការពារកុមារដែលប្រឈមនឹងហានិភ័យដោយសមស្រប នៅគ្រប់ពេលវេលា។ សហការីអង្គការយៃរនឹងផ្ដល់ការណែនាំដល់សហការីអង្គការយៃរឯទៀត ដៃគូ និងភ្ញៀវដើម្បីគោរពតាមស្តង់ដារទាំងនោះ។ ករណីណាមួយនៃការចោទប្រកាន់ពីបទរំលោភបំពាន ឬកេងប្រវ័ញ្ច នឹងត្រូវរាយការណ៍ភ្លាមៗ ឬធ្វើការស៊ើបអង្កេត រួចហើយចាត់វិធានការសមស្រប។

សមត្ថភាពរបស់អង្គការយៃរអូស្ត្រាលីនៅក្នុងការធានាការពារ និងផ្តល់ជំនួយដល់កុមារដែលយើងខ្ញុំធ្វើការជាមួយ វាអាស្រ័យលើសមត្ថភាពនៃសហការីអង្គការយៃរ និងបុគ្គលិករបស់ដៃគូនៅក្នុងការតម្កល់ និងលើកកម្ពស់ស្តង់ដារក្រមសីលធម៌វិជ្ជាជីវៈឱ្យខ្ពស់បំផុត។ សហការីអង្គការយៃរ និងដៃគូទទួលខុសត្រូវដោយផ្ទាល់រៀងៗខ្លួន ឬរួមគ្នា និងប្តេជ្ញាចិត្តអនុវត្ត តម្កល់ និងលើកកម្ពស់ស្តង់ដារការពារកុមារដោយសមស្របនៅគ្រប់ពេលវេលាទាំងអស់។ អ្នកគ្រប់គ្រងទទួលខុសត្រូវជាក់លាក់ ក្នុងការតម្កល់ស្តង់ដារទាំងនេះ ដើម្បីធ្វើជាគំរូល្អ រួចហើយបង្កើតបរិយាកាសធ្វើការងារ ដែលគាំទ្រ និងផ្តល់អំណាចដល់សហការីអង្គការយៃរ និងដៃគូ។

មានការទទួលស្គាល់ថាការងាររបស់អង្គការយៃរអូស្ត្រាលី (និងការងាររបស់ដៃគូខ្លួន) ជារឿយៗ ធ្វើឱ្យសហការីអង្គការស្ថិតនៅក្នុងស្ថានភាពដែលគេទុកចិត្ត ឬមានអំណាចគ្រប់គ្រង ពាក់ព័ន្ធនឹងកុមារ ដែលយើងខ្ញុំធ្វើការជាមួយ។ សហការីអង្គការយៃរ ដៃគូ និងភ្ញៀវមានកាតព្វកិច្ចមិនត្រូវរំលោភបំពានទំនុកចិត្ត ឬរំលោភបំពានអំណាចនេះឡើយ។

ក្រមសីលធម៌នេះត្រូវបានរៀបចំឡើងនៅក្នុងគោលបំណងឱ្យវាបំពេញមុខងារជាបទបញ្ញាផ្ទៃក្នុងច្បាស់លាស់ ដើម្បីឱ្យសហការីអង្គការយៃរ និងដៃគូអាចធ្វើសេចក្តីសម្រេចចិត្តប្រកបដោយសីលធម៌ ដែលពួកគេត្រូវធ្វើនៅក្នុងជីវិតការងាររបស់ពួកគេ និងពេលខ្លះ នៅក្នុងជីវិតឯកជនរបស់ពួកគេផងដែរ។

តំណាលគ្នានឹងការទទួលស្គាល់ថាច្បាប់តំបន់ និងទំនៀមទម្លាប់អាចខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ដូច្នេះក្រមសីលធម៌ស្តីពីកិច្ចការពារកុមារនេះ ផ្អែកលើស្តង់ដារច្បាប់អន្តរជាតិ។

ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារអនុវត្តចំពោះសហការី និងដៃគូទាំងអស់របស់អង្គការយៃរ ដែលត្រូវចុះហត្ថលេខាទទួលស្គាល់ការយល់ដឹងរបស់ពួកគេចំពោះក្រមនេះ។ ការល្មើសណាមួយទៅនឹងក្រមសីលធម៌នេះត្រូវចាត់ទុកថាកំហុសធ្ងន់ ហើយអាចនាំឱ្យមានការដាក់វិន័យ ឬការបណ្តេញចេញពីការងារ ដោយអនុលោមតាម វិន័យរបស់អង្គការយៃរអូស្ត្រាលី។

សហការី និងដៃគូទាំងអស់របស់អង្គការយៃរ ទទួលខុសត្រូវក្នុងការលើកទឹកចិត្ត តស៊ូមតិ និងលើកកម្ពស់ការផ្សព្វផ្សាយក្រមសីលធម៌ស្តីពីកិច្ចការពារកុមារនេះ។ ពួកគេក៏មានតួនាទីនៅក្នុងការប្រតិបត្តិ ការត្រួតពិនិត្យ និងពង្រឹងការអនុវត្តស្តង់ដារនៃក្រមនេះដែរ ហើយគួរលើកទឹកចិត្តដល់បុគ្គលឯទៀតឱ្យប្រកាន់ខ្ជាប់ស្តង់ដារទាំងនេះ ហើយត្រូវចូលរួមជាមួយនឹងអង្គការយៃរអូស្ត្រាលីនៅក្នុងការតម្កល់ស្តង់ដារទាំងនេះ។

ជាបុគ្គលិកអង្គការយៃរ ឬជាដៃគូនៃអង្គការយៃរ ខ្ញុំសូមប្តេជ្ញាថា ៖

1. **ប្រព្រឹត្ត (ធ្វើទង្វើ) ចំពោះកុមារទាំងអស់ដោយយុត្តិធម៌ ដោយគោរព និងដោយភាពថ្លៃថ្នូរ**

    1.1. ខ្ញុំត្រូវប្រព្រឹត្តិទៅលើកុមារទាំងអស់ដោយគោរព ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរភេទ យេនឌ័រ ភាសា សាសនា និន្នាការឬទស្សនៈនយោបាយ ប្រជាជាតិ ឬប្រភពកំណើត ទ្រព្យសម្បត្តិ ពិការភាព ឋានៈកំណើត *(វណ្ណៈពីកំណើត)* ឬឋានៈឯទៀត។

    1.2. ខ្ញុំត្រូវខិតខំរក្សា និងការពារសិទ្ធិរបស់កុមារ ហើយធ្វើសកម្មភាពនៅក្នុងលក្ខខណ្ឌមួយដែលធានាថាឧត្តមប្រយោជន៍របស់កុមារត្រូវបានពិចារណាជាអាទិភាព។

2. **តម្កល់សុចរិតភាពរបស់អង្គការយៃរ តាមរយៈការធានាថាឥរិយាបទផ្ទាល់ខ្លួន និងឥរិយាបទបំពេញការងាររបស់ខ្ញុំគឺមានស្តង់ដារខ្ពស់ ឬមើលមកឃើញថាមានស្តង់ដារខ្ពស់**

    2.1. ខ្ញុំត្រូវប្រកាន់យកនូវសុចរិតភាព ការពិត ការលះបង់ និងភាពស្មោះត្រង់នៅក្នុងសកម្មភាពបំពេញការងាររបស់ខ្ញុំ។ ខ្ញុំត្រូវចេះអត់ធ្មត់ គោរព និងគួរសមចំពោះបុគ្គលទាំងអស់ ដែលខ្ញុំប្រាស្រ័យទាក់ទងជាមួយ ទោះនៅក្នុងសមត្ថភាពណាក៏ដោយ រួមទាំងកុមារផង។

    2.2. ខ្ញុំទទួលស្គាល់ថាឥរិយាបទផ្ទាល់ខ្លួនរបស់ខ្ញុំនឹងឆ្លុះបញ្ចាំងអំពីកេរ្តិ៍ឈ្មោះរបស់អង្គការយៃរ ហើយអាចជះឥទ្ធិពលដល់ការយល់ឃើញរបស់សហគមន៍ ដូច្នេះខ្ញុំត្រូវជៀសវាងពីឥរិយាបទមិនសមរម្យដែលអាចនឹងធ្វើឱ្យតម្លៃរបស់អង្គការយៃរធ្លាក់ចុះ ឬខូចខាតដល់។

    2.3. ខ្ញុំយល់ថាកាតព្វកិច្ចចំពោះខ្ញុំ ក្នុងឋានៈជាបុគ្គលមួយរូបដែលមានការជាប់ទាក់ទងជាមួយនឹងអង្គការយៃរអូស្ត្រាលី គឺត្រូវជៀសវាងរាល់សកម្មភាព ឬឥរិយាបទទាំងឡាយណា ដែលអាចបកស្រាយថាជា

[6] ពាក្យថា "សហការីអង្គការយៃរ" "ដៃគូ" និង "ភ្ញៀវ" ត្រូវបានកំណត់និយមន័យនៅក្នុងគោលនយោបាយស្តីពីកិច្ចគាំពារកុមារនៃអង្គការយៃរអូស្ត្រាលី

ការកេងប្រវ័ញ្ច និងការបំពានលើកុមារ។

2.4. ខ្ញុំត្រូវដឹងអំពីឥរិយាបទប្រកាន់យក និងជៀសវាងសកម្មភាព ឬ ឥរិយាបទដែលមើលទៅធ្វើឱ្យមានការយល់ឃើញថាជាការ ការកេងប្រវ័ញ្ច និងការបំពានកុមារ.

## 3. ការពារ និងប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវចំពោះព័ត៌មាន និងធនធាននៃព័ត៌មាន និងធនធានផ្សេងៗទៀត ដែលខ្ញុំអាចប្រើប្រាស់បាន ដោយសារការងាររបស់ខ្ញុំ ឬដោយសារចូលរួមការងារជាមួយនឹងអង្គការយែរ។

3.1. ខ្ញុំនឹងការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ធនធានសម្ភារបស់អង្គការយែរឱ្យបានសមស្រប។ ខ្ញុំនឹងមិនប្រើប្រាស់ធនធានរបស់អង្គការយែរ ដើម្បីកេងប្រវ័ញ្ច បៀតបៀនកុមារ ឬថតរូបអាសអាភាសកុមារឡើយ។

3.2. នៅពេលថតរូប មុនថតវីដេអូអំពីកុមារ ឬ ប្រើប្រាស់រូបភាពរបស់កុមារសម្រាប់គោលបំណងការងារនោះខ្ញុំត្រូវ ៖

- យកចិត្តទុកដាក់ក្នុងការធានាថាប្រពៃណីតាមតំបន់ ឬ ការរឹតត្បិតសម្រាប់ការផលិតឡើងវិញនូវរូបភាពផ្ទាល់ខ្លួន នឹងត្រូវប្រកាន់ខ្ជាប់នៅមុនការថតរូប ឬការថតវីដេអូអំពីកុមារ។
- មុនថតរូប ថតវីដេអូអំពីកុមារ ត្រូវស្នើសុំការយល់ព្រមពីកុមារ ពីឪពុកម្តាយ ឬពីអាណាព្យាបាលកុមារជាមុនសិន ហើយនៅពេលបានទទួលការយល់ព្រមហើយ ត្រូវពន្យល់ថាតើ រូបថត ឬ វីដេអូនេះ នឹងត្រូវប្រើប្រាស់ដោយរបៀបណា។
- ធានាថារូបថត, វីដេអូ, ខ្សែភាពយន្ត និងឌីវីឌី ត្រូវបង្ហាញរូបកុមារប្រកបដោយភាពថ្លៃថ្នូរ និងការគោរព និងមិនស្ថិតនៅក្នុងរូបភាពងាយរងគ្រោះ ទ្រោមៗ ឬបាក់បបខ្លួបខ្លាចឡើយ។ កុមារគួរស្លៀកពាក់សមរម្យ និងមិនស្ថិតនៅក្នុងជំហរ/រាងដែលមើលទៅទាក់ទាញផ្លូវភេទ ឬបាក់បបខ្លួបខ្លាចឡើយ។
- ធានាថារូបភាពទាំងនោះគឺជាការបង្ហាញដោយស្មោះត្រង់អំពីបរិបទ និងស្ថានភាពពិត។
- ធានាថាស្លាកសញ្ញាចិទលើហ្វាល ទិន្នន័យមេតា ឬអត្ថបទពិពណ៌នាមិនបានបង្ហាញអំពីព័ត៌មានអត្តសញ្ញាណរបស់កុមារឡើយ នៅពេលផ្ញើរូបភាពតាមប្រព័ន្ធអេឡិចត្រូនិច ឬផ្សព្វផ្សាយរូបភាពទាំងនោះ នៅក្នុងទម្រង់ណាក៏ដោយ។

3.3. ខ្ញុំត្រូវយកចិត្តទុកដាក់ដោយត្រឹមត្រូវចំពោះគ្រប់ការងារផ្លូវការទាំងអស់ និងមិនកែក្រឡៃព័ត៌មានសំងាត់ណាមួយរបស់កុមារ និងបញ្ហាងទៀតដែលពាក់ព័ន្ធនឹងការងារឡើយ ដោយអនុវត្តតាមបទប្បញ្ញត្តិ វិធានការ និងការណែនាំធរមាននេះ។

## 4. ទប់ស្កាត់ ប្រឆាំង និងប្រយុទ្ធជាមួយនឹងការកេងប្រវ័ញ្ច និងការបំពានគ្រប់ទម្រង់ទាំងអស់មកលើកុមារ

4.1. ខ្ញុំមិនត្រូវរំលោភបំពានកុមារឡើយ ដូចជារំលោភបំពានផ្លូវកាយ ផ្លូវភេទ និងកេងប្រវ័ញ្ចកុមារឡើយ។

4.2. ខ្ញុំអះអាងថានឹងមិនរំលោភបំពានអំណាច និងប្រើប្រាស់ឥទ្ធិពលរបស់ខ្ញុំ ដែលខ្ញុំមាន តាមរយៈមុខតំណែងរបស់ខ្ញុំនេះ ទៅលើជីវិតនិងសុខុមាលភាពរបស់កុមារឡើយ។

4.3. ខ្ញុំត្រូវរាយការណ៍រាល់ករណីសង្ស័យ កង្វល់ ឬការចោទប្រកាន់ ឬការកេងប្រវ័ញ្ចនិងការបំពានលើកុមារ ដែលប្រព្រឹត្តិឡើងដោយបុគ្គលិកអង្គការយែរ ឬដោយដៃគូ ឬដោយភ្ញៀវ។

4.4. ខ្ញុំមិនត្រូវប្រើប្រាស់ភាសា ឬធ្វើទង្វើចំពោះកុមារ ដោយមិនសមរម្យ បៀតបៀន បំពាន ជម្រុញចំណង់ផ្លូវភេទ ទាមទារសុំ ឬ ធ្វើទង្វើណាមិនសមស្របតាមវប្បធម៌សម្រាប់កុមារឡើយ។

4.5. ខ្ញុំមិនត្រូវសុំសេវា (ការជួយ) ណាមួយ ឬការអនុគ្រោះពីកុមារឡើយ ជាថ្នូរនឹងការការពារ ឬការជួយចំពោះកុមារវិញ។ ខ្ញុំនឹងមិនចូលពាក់ព័ន្ធទៅក្នុងការទាក់ទងណាមួយបែបកេងប្រវ័ញ្ចឡើយ--ទំនាក់ទំនងផ្លូវភេទ ផ្លូវអារម្មណ៍ ផ្លូវហិរញ្ញវត្ថុ ឬពាក់ព័ន្ធនឹងការធ្វើការងារជាដើម--ជាមួយកុមារឡើយ។

4.6. ខ្ញុំមិនត្រូវជួលកុមារដើម្បីធ្វើការផ្ទះ ឬការងារពលកម្មណាមួយឡើយ ដែលវាមិនសមរម្យ បើគិតលើអាយុ ឬដំណាក់កាលលូតលាស់របស់កុមារ ដែលនេះវាធ្វើឱ្យប៉ះពាល់ដល់ពេលវេលារបស់កុមារសម្រាប់ការសិក្សា និងសកម្មភាពលេងកំសាន្តនានា ឬ ដែលធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យខ្ពស់ពីការរងគ្រោះថ្នាក់។

4.7. នៅក្នុងករណីអាចធ្វើបាន ខ្ញុំត្រូវធានាថាមានមនុស្សពេញវ័យម្នាក់ទៀតមានវត្តមាននៅជាមួយដែរ នៅពេលធ្វើការជិតកុមារ។

4.8. ខ្ញុំមិនត្រូវហៅកុមារដែលគ្មានអ្នកទៅជាមួយ ចូលទៅក្នុងលំនៅដ្ឋានឯកជន លើកលែងតែកុមារប្រឈមនឹងការរងគ្រោះថ្នាក់ ឬគ្រោះថ្នាក់ដល់រូបរាងកាយ។

4.9. ខ្ញុំមិនត្រូវដេកជិតកុមារដែលគ្មានអ្នកនៅមើល លើកលែងតែចាំបាច់ដាច់ខាត ដែលក្នុងករណីបែបនេះ ខ្ញុំត្រូវសុំការអនុញ្ញាតពីប្រធានរបស់ខ្ញុំជាមុនសិន ហើយត្រូវឱ្យមានមនុស្សពេញវ័យណាម្នាក់ទៀតមានវត្តមាននៅជាមួយដែរ បើអាចធ្វើបាន (សូមកត់សម្គាល់ថាខសន្យានេះមិនអនុវត្តចំពោះកុមារ

ដែលជាកូនចៅផ្ទាល់នោះទេ)។

4.10. ខ្ញុំមិនត្រូវស្ថិតនៅក្រោមឥទ្ធិពលស្រា ឬគ្រឿងញៀនឡើយ នៅពេលប្រាស្រ័យទាក់ទងជាមួយនឹងកុមារដែលគ្មានអ្នកនៅមើលឡើយ (សូមកត់សម្គាល់ថាខសន្យានេះមិនអនុវត្តចំពោះ កុមារដែលជាកូនចៅផ្ទាល់នោះទេ)។

4.11. ខ្ញុំមិនត្រូវប្រើប្រាស់ការដាក់ទណ្ឌកម្មរូបកាយមកលើកុមារឡើយ។ ខ្ញុំមិនត្រូវមានឥរិយាបទណាមួយដែលធ្វើឱ្យអាម៉ាស់ ធ្វើឱ្យអាប់មុខ បន្ទាបបន្ថោក ឬមិនឱ្យតម្លៃកុមារ ឬក្មេងជំទង់ ឬរំលោភបំពានផ្លូវអារម្មណ៍ ឬផ្លូវចិត្តកុមារ ឬក្មេងជំទង់ឡើយ ដែលមានដូចជាការបញ្ចូនពួកគេឱ្យទៅរស់នៅជាមួយគ្រួសារហិង្សា។

4.12. ខ្ញុំមិនត្រូវប្រើប្រាស់កុំព្យូទ័រ ទូរស័ព្ទដៃ កាមេរ៉ាវីដេអូ កាមេរ៉ាថត ឬបណ្តាញសង្គមដោយមិនសមរម្យឡើយ ហើយក៏មិនត្រូវប្រើប្រាស់ឧបករណ៍ទាំងនោះដើម្បីកេងប្រវ័ញ្ច ឬបៀតបៀនកុមារ ឬចូលប្រើប្រាស់ឯកសារព័ត៌មានកេងប្រវ័ញ្ចកុមារទោះតាមមធ្យោបាយណាមួយក៏ដោយ។

4.13. ខ្ញុំមិនត្រូវប្រើប្រាស់បណ្តាញសង្គមដោយមិនសមរម្យ ដើម្បីទាក់ទង ជួប រាប់អាន ឬធ្វើជាមិត្តភក្តិជាមួយនឹងកុមារដែលពាក់ព័ន្ធនៅក្នុងគម្រោង ឬនៅក្នុងសកម្មភាព ដែលផ្តល់ថវិកាឬគ្រប់គ្រងដោយអង្គការយែរ និងប្រើប្រាស់មិនត្រឹមត្រូវនូវរូបភាពកុមារទាំងនោះនៅលើវែបសាយបណ្តាញសង្គមផ្ទាល់ខ្លួនឡើយ (ឧ.ផ្សព្វផ្សាយកុមារនៅតាមប្រព័ន្ធអនឡាញ)។

## 5. ជៀសវាងពីការជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពព្រហ្មទណ្ឌ ឬអសីលធម៌ណាមួយ ឬ សកម្មភាពទាំងឡាយណាដែលប្រឆាំងនឹងសិទ្ធិមនុស្ស ឬ សកម្មភាពទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់រូបភាព និងប្រយោជន៍នៃអង្គការយែរ។

5.1. ខ្ញុំមិនត្រូវគាំទ្រ ឬចូលរួមនៅក្នុងសកម្មភាពខុសច្បាប់ កេងប្រវ័ញ្ច ឬបំពានទោះក្នុងទម្រង់ណាមួយក៏ដោយ ដែលមានដូចជា ពលកម្មកុមារ ការថតរូបអាសអាភាសកុមារ និងការជួញដូរមនុស្សនិងរបស់របរមានតម្លៃឡើយ។

5.2. ខ្ញុំមិនត្រូវឱ្យកុមារដែលមានអាយុក្រោម 18 ឆ្នាំចូលពាក់ព័ន្ធនៅក្នុងការរួមភេទទោះក្នុងទម្រង់ណាមួយក៏ដោយ ឬចូលរួមនៅក្នុងសកម្មភាពផ្លូវភេទឡើយ រួមមានដូចជាការឱ្យលុយដើម្បីបានសេវាផ្លូវភេទជាដើម។ ចំណុចនេះមិនគិតអំពីអាយុអាចយល់ព្រមបាន នៅតាមតំបន់ ឬច្បាប់ប្រទេសដែលខ្ញុំធ្វើការនៅទីនោះទេ។ ការមិនដឹង ឬការយល់ខុសអំពីអាយុរបស់កុមារមិនអាចជាមូលហេតុសម្រាប់ការពារខ្លួននោះទេ។ ការខកខានមិនបានរាយការណ៍អំពីទំនាក់ទំនងនោះ អាចនឹងនាំឱ្យមានការចាត់វិធានការដាក់វិន័យ យោងតាមគោលនយោបាយ និងនីតិវិធីនៃអង្គការយែរអូស្រ្តាលី។ ខ្ញុំត្រូវគោរពតាមបទប្បញ្ញត្តិគតិយុទ្ធពាក់ព័ន្ធទាំងអស់របស់ប្រទេសអូស្រ្តាលី និងរបស់តំបន់ដែលខ្ញុំធ្វើការ រួមមានច្បាប់ស្តីពីការងារ ទាក់ទិននឹងពលកម្មកុមារជាដើម។

## 6. ការលាតត្រដាងប្រាប់ និងតម្លាភាព

6.1. ខ្ញុំនឹងលាតត្រដាងប្រាប់ភ្លាមៗអំពីការចោទប្រកាន់ទាំងអស់ ការកាត់ទោស និងលទ្ធផលនៃការប្រព្រឹត្តិបទល្មើស ដែលបានកើតឡើងកាលពីមុន ឬកើតឡើងនៅអំឡុងពេលធ្វើការរួមគ្នាជាមួយនឹងអង្គការយែរ ដែលទាក់ទិននឹងការកេងប្រវ័ញ្ច និងការបំពានកុមារ រួមទាំងនៅក្រោមច្បាប់ប្រពៃណីផងដែរ។

6.2. ខ្ញុំត្រូវរាយការណ៍អំពីការប្រែប្រួលស្ថានភាពផ្ទាល់ខ្លួនរបស់ខ្ញុំខាងក្រោមនេះ ទៅថ្នាក់គ្រប់គ្រង ៖

- ការជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពឧក្រិដ្ឋ
- ការទទួលរងវិន័យ
- ការចោទប្រកាន់ នីតិវិធីតុលាការទៅលើបទល្មើសរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងការបំពានកុមារ

## 7. ការរាយការណ៍អំពីកង្វល់ ការសង្ស័យ ឬការចោទប្រកាន់

7.1. ខ្ញុំត្រូវរាយការណ៍ភ្លាមៗអំពីកង្វល់ ការសង្ស័យ ឬការចោទប្រកាន់ករណីកេងប្រវ័ញ្ច និងបំពានកុមារ និងការមិនអនុវត្តគោលនយោបាយ ដោយអនុលោមតាមនីតិវិធីសមស្រប។

**ឧបសម្ព័ន្ធ** 3

## ការទទួលស្គាល់ថាបានការទទួលក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ

ខ្ញុំទទួលស្គាល់ថាខ្ញុំពិតជាបានទទួល បានអាន និងបានយល់អំពីគោលនយោបាយស្តីពីកិច្ចការពារកុមារ និងក្រមសីលធម៌ស្តីពីកិច្ចការពារកុមាររបស់អង្គការយៃអូស្ត្រាលី ហើយយល់ព្រមគោរពតាម តម្កល់ និង លើកកម្ពស់ ស្តង់ដារកិច្ចការពារកុមារដែលប្រឈមនឹងហានិភ័យដោយសមស្របនៅគ្រប់ពេលវេលាទាំងអស់។

ខ្ញុំក៏យល់ផងដែរថាការប្រព្រឹត្តិល្មើសនឹងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារនេះនឹងនាំឱ្យមានវិធានការដាក់វិន័យ ឬការបណ្តេញចេញពីការងារ ដោយអនុវត្តតាមវិន័យទាំងនោះរបស់អង្គការយៃអូស្ត្រាលី ហើយក៏អាចនឹងនាំឱ្យមានការកាត់ទោសពីបទព្រហ្មទណ្ឌផងដែរ។

________________________________________

(ឈ្មោះ)

________________________________________

(ហត្ថលេខា)

________________________________________

(កាលបរិច្ឆេទ)